ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ឧបសម្ព័ន្ធ

# ស្តីពី

# សញ្ញាចរាចរណ៍ផ្លូវគោក


ក្រសួងសាធារណការ និងដឹកជញ្ជូន

MINISTRY OF PUBLIC WORKS
AND TRANSPORT

# ឧបសម្ព័ន្ធ
# ស្តីពី
# សញ្ញាចរាចរណ៍ផ្លូវគោក

## សញ្ញាចរាចរណ៍ផ្លូវគោកមាន

ក. ផ្លាកសញ្ញាចរាចរណ៍

ខ. ភ្លើងសញ្ញាចរាចរណ៍

គ. គំនូសសញ្ញាចរាចរណ៍

ឃ. សញ្ញាបញ្ជារបស់ភ្នាក់ងារនគរបាលចរាចរណ៍

# ក. ផ្លាកសញ្ញាចរាចរណ៍ (ROAD SIGNS)

## I. ផ្លាកសញ្ញានិយ័ត (REGULATORY SIGNS)

### I(i)- ផ្លាកសញ្ញាបំរាម (Prohibitory Signs)


R1-01


R1-02


R1-03


R1-04


R1-05


R1-06



R1-07



R1-08



R1-09



R1-10



R1-11


R1-12


R1-13


R1-14


R1-15


R1-16


R1-17


R1-18


R1-19


R1-20



R1-21



R1-22



R1-23



R1-24


R1-25


R1-26


R1-27


R1-28


R1-29


R1-30


W1-41


W1-42


W1-43


W1-44


W1-45


W1-46


W1-47


W1-48


W1-49

**II(ii)-** ផ្លាកសញ្ញាប្រើបណ្តោះអាសន្ន (Temporary Signs)


W2-01


W2-02


W2-03



W2-04



W2-05



W2-06


W2-07


W2-08



W2-09


W2-10


W2-11

# III. ផ្លាកសញ្ញាប្រាប់ដំណឹង (GUIDE SIGNS)

## III(i)- ផ្លាកសញ្ញាបង្ហាញទិសដៅ (Direction Signs)




G1-01




G1-02




G1-03




G1-04




G1-05




G1-06

## III(ii)- ផ្លាកសញ្ញាប្រាប់ទីប្រជុំជន និងព្រំប្រទល់តំបន់ (Buildup Area and Boundary Signs)







G2-01







G2-02







G2-03







G2-04

## III(iii)- ផ្លាកសញ្ញាប្រាប់ឈ្មោះផ្លូវ (Street Name Signs)




G3-01




G3-02




G3-03




G3-04

# V. បង្គោលសញ្ញា (SIGN POSTS)



P1-01



P1-02



P1-03



P1-04



P1-05



P1-06



P1-07




P1-08




P1-09




P1-10

## ខ. ភ្លើងសញ្ញាចរាចរណ៍ (TRAFFIC LIGHTS)

### ប្រភេទទី១. ភ្លើងសញ្ញាចរាចរណ៍បីពណ៌ (THREE COLORED TRAFFIC LIGHTS)



L1-01



L1-02



L1-03



L1-04



L1-05



L1-06



L1-07




L1-08

### ប្រភេទទី២. ភ្លើងសញ្ញាចរាចរណ៍ពីរពណ៌ (TWO COLORED TRAFFIC LIGHTS)



L2-01

### ប្រភេទទី៣. ភ្លើងសញ្ញាចរាចរណ៍មួយពណ៌ (ONE COLORED TRAFFIC LIGHTS)



L3-01



L3-02

## គ- គំនូសសញ្ញាចរាចរណ៍ (ROAD MARKINGS)

### I- គំនូសសញ្ញាព័ណ៌សកាត់ទទឹងផ្លូវ (TRANSVERSE MARKINGS)



M1-01 M1-02 M1-03 M1-04

### II- គំនូសសញ្ញាតាមបណ្តោយទ្រូវផ្លូវ (LONGITUDINAL MARKINGS)



M2-01 M2-02 M2-03 M2-04 M2-05 M2-06 M2-07



M2-08 M2-09 M2-10 M2-11

### III- គំនូសសញ្ញាព្រួញលើទ្រូវផ្លូវ (ARROW MARKINGS)



M2-01 M2-02 M2-03 M2-04 M2-05 M2-06 M2-07 M2-08

## IV- គំនូសសញ្ញាផ្សេងៗលើផ្ទៃផ្លូវ (OTHER ROAD MARKINGS)


M4-01


M4-02


M4-03


M4-04


M4-05


M4-06


M4-07


M4-08


M4-09

## ឃ- សញ្ញាបញ្ជារបស់ភ្នាក់ងារនគរបាលចរាចរ (TRAFFIC POLICE SIGNALS)


O1-01


O1-02


O1-03


O1-04


O1-05

# សញ្ញាចរាចរណ៍

សញ្ញាចរាចរណ៍ ប្រើដើម្បីជួយធានាសុវត្ថិភាពចរាចរណ៍ ដោយធ្វើឱ្យចលនាចរាចរណ៍ទាំងអស់មានសណ្តាប់ធ្នាប់ និងផ្តល់នូវការនាំផ្លូវ ប្រាប់ដំណឹងគ្រោះថ្នាក់ ឬ ដំណឹងផ្សេងៗ ដែលពាក់ព័ន្ធនឹងការធ្វើចរាចរ។ ដូចច្នេះ អ្នកប្រើប្រាស់ផ្លូវត្រូវតែគោរពសញ្ញាចរាចរណ៍ឱ្យបានម៉ឺងម៉ាត់បំផុត ទើបអាចជៀងសរាងគ្រោះថ្នាក់ជាយថាហេតុបាន។

ប្លង់លម្អិតអំពី រូបភាព ទំហំ សូមមើលឧបសម្ព័ន្ធស្តីអំពី សញ្ញាចរាចរណ៍ផ្លូវគោក ភាគ២ ៖ លម្អិតសម្រាប់ការងារសាងសង់។

សញ្ញាចរាចរណ៍មាន ៤ ប្រភេទ ៖

**ក.** **ផ្លាកសញ្ញាចរាចរណ៍**

**ខ.** **ភ្លើងសញ្ញាចរាចរណ៍**

**គ.** **គំនូសសញ្ញាចរាចរណ៍**

**ឃ.** **សញ្ញាបញ្ជារបស់ភ្នាក់ងារនគរបាលចរាចរណ៍**

# ក - ផ្លាកចរាចរណ៍

## ROAD SIGNS

## I. មូលដ្ឋានគ្រឹះនៃផ្លាកសញ្ញាចរាចរណ៍

### I.1 លក្ខណៈទូទៅ

ផ្លាកសញ្ញាចរាចរណ៍ ត្រូវបានបង្កើតឡើងក្នុងគោលបំណង ធ្វើឱ្យចរាចរណ៍លើផ្លូវសាធារណៈ មានរបៀបរៀបរយ ងាយស្រួលក្នុងការបើកបរ និងធានាសុវត្ថិភាព។ ផ្លាកសញ្ញាចរាចរណ៍ទាំងនេះ ត្រូវបានបែងចែកជាប្រភេទផ្សេងៗពីគ្នាច្បាស់លាស់។ ប្រភេទខ្លះប្រើក្នុងការណែនាំដល់អ្នកធ្វើចរាចរណ៍លើផ្លូវសាធារណៈឱ្យគោរពប្រតិបត្តិតាម ខ្លះជាប្រភេទសញ្ញាប្រាប់ឱ្យដឹងមុននូវគ្រោះថ្នាក់ជាយថាហេតុនានានៅលើដងផ្លូវ និងប្រភេទខ្លះទៀត សម្រាប់ផ្តល់ព័ត៌មាន ពីទីកន្លែងផ្សេងៗ ឬបង្ហាញទិសដៅ និងទីកន្លែងស្រុក ភូមិសំខាន់ៗ។ល។

ផ្លាកសញ្ញានីមួយៗ ត្រូវបានកំណត់ឡើងដោយ <u>ទ្រង់ទ្រាយ</u> <u>សញ្ញាសម្គាល់</u> និង <u>ព័ណ៌</u> ផ្សេងៗពីគ្នា។ សញ្ញាសម្គាល់អាចជា លេខ ឬជា និមិត្តរូប ឬអាចទាំងពីរព្រមគ្នា។

ពិតមែនតែផ្លាកសញ្ញា គឺជាផ្នែកដ៏សំខាន់ចាំបាច់នៃប្រព័ន្ធចរាចរណ៍ តែការដាក់ប្រើប្រាស់សញ្ញានីមួយៗ ក៏ត្រូវសិក្សាពីទីតាំងភូមិសាស្ត្រផ្លូវឱ្យបានល្អិតល្អន់។ រីឯបទដ្ឋានកម្មនៃ <u>ទ្រង់ទ្រាយ</u> <u>សញ្ញាសម្គាល់</u> និង <u>ព័ណ៌</u> របស់សញ្ញានីមួយៗ ត្រូវបានកំណត់ឡើងឱ្យមានលក្ខណៈងាយយល់ងាយចាំ។

## I .2 ទ្រង់ទ្រាយ



- រាងជាអដ្ឋកោណនិយ័ត 9 ជ្រុង8ស្មើគ្នា ប្រើសំរាប់សញ្ញា :
  ផ្តល់សិទ្ធិអាទិភាពអោយគេ ( STOP AND GIVE WAY SIGN )



- រាងជាត្រីកោណសម័ង្សដែលមានកំពូលមួយចុះក្រោមប្រើសំរាប់សញ្ញា :
  ផ្តល់សិទ្ធិអាទិភាពអោយគេ  ( GIVE WAY SIGN )



- រាងជាការេដែលមានជ្រុងពីរជាបន្ទាត់ឈរ និងជ្រុងពីរទៀតជាបន្ទាត់ដេក
  ប្រើសំរាប់សញ្ញា : ប្រាប់ដំណឹង  ( GUIDE SIGNS )



- រាងជារង្វង់ប្រើសំរាប់សញ្ញា : និយ័ត  ( REGULATORY SIGNS ) :
  - ពណ៌ក្រហមជាសញ្ញាបំរាម ( Prohibitory Signs )
  - ពណ៌ខៀវជាសញ្ញាបញ្ជា ( Mandatory Signs )



- រាងជាការេដែលមានអង្កត់ទ្រូងមួយជាបន្ទាត់ឈរ និងអង្កត់ទ្រូងមួយទៀត
  ជាបន្ទាត់ដេកប្រើសំរាប់សញ្ញា : គ្រោះថ្នាក់  ( WARNING SIGNS )



- រាងជាបន្ទាត់ខ្វែងប្រើសំរាប់សញ្ញា : មានផ្លូវរថភ្លើងកាត់
  ( RAILWAY LEVEL CROSSING)



- រាងជាចតុកោណកែងដែលមានជ្រុងដេកវែងជាងជ្រុងឈរប្រើសំរាប់សញ្ញា :
  បណ្តោះអាសន្ន  ( Temporary Signs ) ដូចជាមានការដ្ឋាន
  បង្ហាញទិសដៅ ឬ ប្រាប់ឈ្មោះតំបន់ ( Guide Signs, Place name Signs etc.)
  ឬសញ្ញាបញ្ជាក់បន្ថែមពីក្រោមសញ្ញាដទៃទៀត ( Supplementary Signs )



- រាងដូចនេះប្រើសំរាប់ កំណត់ប្រភេទផ្លូវ ដូចជា :
  ទី1 ជាផ្លូវជាតិ        (National Road)
  ទី2 ជាផ្លូវតំបន      (Highway)
  ទី3 ជាផ្លូវយន្តបថ  (Motor way)

## II . ការបែងចែកប្រភេទសញ្ញា

ផ្លាកសញ្ញាទាំងអស់ត្រូវបានបែងចែកជា **ប្រាំផ្នែក** ធំៗដូចខាងក្រោម :

### ផ្នែកទី I : សញ្ញានិយ័ត ( Regulatory Signs )

ក្នុងផ្នែកទី I នេះត្រូវបានបែងចែកជាផ្នែករង បួន គឺ :

- **I ( i )** សញ្ញាបំរាម ( Prohibitory Signs )
  លេខសំគាល់ : **PW03-R1-00**
- **I ( ii )** សញ្ញាបញ្ជា ( Mandatory Signs )
  លេខសំគាល់ : **PW03-R2-00**
- **I ( iii )** សញ្ញាបង្ហាញពីសិទ្ធអាទិភាព ( Priority Signs )
  លេខសំគាល់ : **PW03-R3-00**

### ផ្នែកទី II : សញ្ញាគ្រោះថ្នាក់ ( Warning Signs )

ក្នុងផ្នែកទី II នេះត្រូវបានបែងចែកជាផ្នែករង ពីរ គឺ :

- **II ( i )** សញ្ញាគ្រោះថ្នាក់ ( Warning Signs )
  លេខសំគាល់ : **PW03-W1-00**
  ប្រើរយៈពេលវែងប្រាប់ពីគ្រោះថ្នាក់ផ្សេងៗដែលអាចកើតមានជាយថាហេតុ
- **II ( ii )** សញ្ញាប្រើបណ្តោះអាសន្ន ( Temporary Signs )
  លេខសំគាល់ : **PW03-W2-00**
  ប្រើក្នុងរយៈពេលមានការដ្ឋានជួសជុល ឬ សាងសង់ផ្លូវថ្នល់ ។ល។

## ផ្នែកទី III : សញ្ញាប្រាប់ដំណឹង ( Guide Signs )

ក្នុងផ្នែកទី III នេះត្រូវបានបែងចែកជាផ្នែករង បួន គឺ :

- **III ( i )** សញ្ញាបង្ហាញទិសដៅ ( Direction Signs )
  លេខសំគាល់ : **PW03-G1-00**
- **III ( ii )** សញ្ញាប្រាប់ទីប្រជុំជន និងព្រំប្រទល់តំបន់ ( Buildup Area and Boundary Signs )
  លេខសំគាល់ : **PW03-G2-00**
- **III ( iii )** សញ្ញាប្រាប់ឈ្មោះផ្លូវ ( Street name Signs )
  លេខសំគាល់ : **PW03-G3-00**
- **III ( iv )** សញ្ញាផ្តល់ដំណឹង ( Services Signs )
  លេខសំគាល់ : **PW03-G4-00**

## ផ្នែកទី IV : សញ្ញាបន្ថែម ( Supplementary Signs )

សញ្ញានេះសំរាប់ដាក់បន្ថែមពីក្រោមសញ្ញាដទៃទៀត :

- **IV ( i )** សញ្ញាដាក់បន្ថែមពីក្រោម ( Supplementary Signs )
  លេខសំគាល់ : **PW03-S1-00**

## ផ្នែកទី V : បង្គោលសញ្ញា ( Sign Posts )

សញ្ញានេះសំរាប់តំរង់ផ្លូវ ឬ បង្ហាញឧបសគ្គ :

- **V ( i )** បង្គោលសញ្ញា ( Sign Posts )
  លេខសំគាល់ : **PW03-P1-00**

## III . ទីតាំងផ្លាកសញ្ញា

ការដាក់តាំងផ្លាកសញ្ញានិមួយៗត្រូវជ្រើសរើសទីតាំង ភូមិសាស្រ្តផ្លូវ អោយបានល្អិតល្អន់ ដើម្បី រក្សាសុវត្ថិភាពចរាចរ និង ងាយចាប់អារម្មណ៏ដល់អ្នកបើកបរយានជំនិះគ្រប់ប្រភេទ ។ ទីតាំងទាំងនោះ ត្រូវបានកំណត់ដូចក្នុងរូបភាពខាងក្រោម នេះ :

## III.1 ផ្លូវក្នុងក្រុង

ការដាក់ផ្លាកសញ្ញានៅលើចិញ្ចើមផ្លូវក្នុងទីក្រុង ត្រូវរក្សាចន្លោះមិនតិចជាង ០.៦០ម៉ែត្រ ពី គែមផ្លូវមកទល់នឹងផ្លាកសញ្ញា និងរក្សាកំពស់មិនទាបជាង ២.១០ ម៉ែត្រ ពីផ្លាកសញ្ញាមកដល់ការូឡា ។




## III.2 ផ្លូវជាតិ

ការដាក់ផ្លាកសញ្ញានៅលើចិញ្ចើមផ្លូវជាតិ ត្រូវរក្សាចំងាយក្នុងចន្លោះពី ០.៦០...១.៨០ម៉ែត្រ ពី គែមផ្លូវមកទល់នឹងផ្លាកសញ្ញា និងរក្សាកំពស់ក្នុងចន្លោះពី ១.២០...១.៥០ ម៉ែត្រ ពីផ្លាកសញ្ញា មកទល់នឹងកំរិតកំពស់របស់ផ្លូវ ។



## III.3 ដាក់ព្យួរពីលើ

ការព្យួរផ្លាកសញ្ញាលើរបា ត្រូវមានកំពស់មិនទាបជាង ៥.00 ម៉ែត្រ ពីផ្លាកសញ្ញា មកដល់ទ្រូងផ្លូវ ហើយត្រូវដាក់អោយចំគន្លងផ្លូវនិមួយៗ ដើម្បីអោយអ្នកបើកបរ ងាយចាប់ អារម្មណ៍ ។



# ផ្នែកទី I ( i )

# ផ្លាកសញ្ញាបំរាម

## Prohibitory signs

ផ្លាកសញ្ញាបំរាមមានរាងមូល មានជាយពទ្ធ័ជុំវិញពីរជាន់ ជាយក្នុងក្រាស់មានពណ៌ក្រហមក្រាស់ ជាយក្រៅ ស្តើងមានពណ៌ស ឯសញ្ញាសំគាល់ខាងក្នុងជាទូទៅមានពណ៌ខ្មៅ ។ ក្នុងករណីខ្លះត្រូវប្រើសញ្ញា ចប់ការហាម ឃាត់ ដែលមានរាងមូលដូចគ្នា តែមានពណ៌ខ្មៅទាំងអស់ ។

ផ្លាកសញ្ញាប្រភេទនេះ ដាក់បំរាមដល់អ្នកបើកបរមិនអោយប្រព្រឹត្តិនូវអ្វី ដែលមានបញ្ជាក់នៅក្នុង សញ្ញា ដូចជា ហាមបត់ឆ្វេង ហាមបត់ស្តាំ ហាមចត ។ល។ ដូចនេះបើអ្នកបើកបរ ឃើញផ្លាកសញ្ញាប្រភេទនេះ ត្រូវ អនុវត្ត តាមជាដាច់ខាត ។



**ហាមបត់ឆ្វេង**

NO TURN LEFT

**លេខកូដ : PW03-R1-01**

**ខ្លឹមសារ** : សញ្ញានេះ ហាមយានជំនិះគ្រប់ប្រភេទ បត់ឆ្វេង ។

---



**ហាមបត់ស្តាំ**

NO TURN RIGHT

**លេខកូដ : PW03-R1-02**

**ខ្លឹមសារ** : សញ្ញានេះ ហាមយានជំនិះគ្រប់ប្រភេទ បត់ស្តាំ ។

---



**ហាមបត់ត្រឡប់ក្រោយ**

NO **U** TURN

**លេខកូដ : PW03-R1-03**

**ខ្លឹមសារ** : សញ្ញានេះ ហាមយានជំនិះគ្រប់ប្រភេទ បត់ត្រឡប់ក្រោយ ។

---



**ហាមចូល**

NO ENTRY

**លេខកូដ : PW03-R1-04**

**ខ្លឹមសារ** : សញ្ញានេះ ហាមចូលចំពោះយានជំនិះគ្រប់ប្រភេទ ។



**ផ្លូវបិទចំពោះយានជំនិះគ្រប់ប្រភេទ**

CLOSED FOR ALL VEHICLES

**លេខកូដ : PW03-R1-05**

**ខ្លឹមសារ** : ផ្លូវបិទ ចំពោះយានជំនិះគ្រប់ប្រភេទ ។



**ផ្លូវបិទ ចំពោះអ្នកប្រើប្រាស់ផ្លូវ**

CLOSED FOR ALL ROAD USERS

**លេខកូដ : PW03-R1-06**

**ខ្លឹមសារ** : ផ្លូវបិទចំពោះអ្នកប្រើប្រាស់ផ្លូវ
(ហាមយានជំនិះគ្រប់ប្រភេទ និង ថ្មើរជើងធ្វើចរាចរ) ។




**កំណត់ទំងន់សរុប**

TOTAL WEIGHT LIMIT

**លេខកូដ : PW03-R1-07**

**ខ្លឹមសារ** : សញ្ញានេះ ហាមចូលចំពោះយានជំនិះដែលមានទំងន់សរុបគិតទាំងបន្ទុក លើសទំងន់កំណត់ក្នុង ផ្ទាកសញ្ញា។




**កំណត់ទំងន់ផ្ទុកលើភ្លៅនិមួយៗ**

WEIGHT LIMIT ON ONE AXLE

**លេខកូដ : PW03-R1-08**

**ខ្លឹមសារ** : សញ្ញានេះ ហាមចូលចំពោះយានជំនិះដែលមានទំងន់ផ្ទុកលើភ្លៅ ( ប៉ុង ) និមួយៗ លើសពីការកំណត់ក្នុង ផ្ទាក សញ្ញា ។




**កំណត់កំពស់**

HEIGHT LIMIT

**លេខកូដ : PW03-R1-09**

**ខ្លឹមសារ** : សញ្ញានេះហាមចូលចំពោះយានជំនិះដែលមាន កំពស់ សរុប គិតទាំងបន្ទុក លើសកំពស់កំណត់ ក្នុងផ្លាក សញ្ញា ។

---




**កំណត់ទទឹង**

WIDTH LIMIT

**លេខកូដ : PW03-R1-10**

**ខ្លឹមសារ** : សញ្ញានេះ ហាមចូលចំពោះយានជំនិះ ដែលមាន ទទឹង សរុប គិតទាំងបន្ទុក លើសប្រវែងកំណត់ ក្នុងផ្លាក សញ្ញា ។

---




**កំណត់បណ្តោយ**

LENGHT LIMIT

**លេខកូដ : PW03-R1-11**

**ខ្លឹមសារ** : សញ្ញានេះ ហាមចូលចំពោះយានជំនិះ ដែលមាន បណ្តោយ សរុប គិតទាំងបន្ទុក លើសប្រវែងកំណត់ ក្នុងផ្លាកសញ្ញា ។

---



**ហាមចូលចំពោះទោចក្រយាន**
**ទោចក្រយានយន្ត និង ត្រីចក្រយាន**

NO ENTRY FOR BICYCLE , MOTORCYCLE
AND TRICYCLE

**លេខកូដ : PW03-R1-12**

**ខ្លឹមសារ** : សញ្ញានេះ ហាមចូលចំពោះ ទោចក្រយាន, ទោចក្រយានយន្ត និង ត្រីចក្រយាន ។



**ហាមចូលចំពោះ  ទោចក្រយានយន្ត**

NO ENTRY FOR  MOTORCYCLE

**លេខកូដ : PW03-R1-13**

**ខ្លឹមសារ** : សញ្ញានេះ ហាមចូលចំពោះទោចក្រយានយន្ត។

---



**ហាមចូលចំពោះយានយន្តគ្រប់ប្រភេទ**
**លើកលែងតែទោចក្រយានយន្ត**

NO ENTRY FOR MOTOR VEHICLES EXCEPT
MOTORCYCLES WITHOUT SIDE CARTS

**លេខកូដ : PW03-R1-14**

**ខ្លឹមសារ** : សញ្ញានេះ ហាមចូលចំពោះ យានយន្តគ្រប់ប្រភេទ លើកលែងតែ ទោចក្រយានយន្ត ដែលគ្មានភ្ជាប់រ៉ឺម៉ក សណ្តោង ឬ រ៉ឺម៉កចំហៀង។

---



**ហាមចូលចំពោះរថយន្តដឹកទំនិញធុនធំ**

NO ENTRY FOR LARGED-SIZED TRUCK

**លេខកូដ : PW03-R1-15**

**ខ្លឹមសារ** : សញ្ញានេះ ហាមចូលចំពោះ រថយន្តដឹកទំនិញធុនធំដែលជាប្រភេទរថយន្ត មានទំងន់សរុបលើស ៣.៥០តោន ។

---



**ហាមចូលចំពោះរថយន្តដឹកអ្នកដំណើរធុនធំ**

NO ENTRY FOR LARGED-SIZED BUS

**លេខកូដ : PW03-R1-16**

**ខ្លឹមសារ** : សញ្ញានេះ ហាមចូលចំពោះ រថយន្តដឹកអ្នកដំណើរធុនធំ ដែលជា ប្រភេទរថយន្ត ផ្ទុកអ្នកដំណើរលើសពី ២០ នាក់ គិតទាំងអ្នកបើកបរ ។



**ហាមចូលចំពោះយានយន្តគ្រប់ប្រភេទ**

NO ENTRY FOR MOTOR VEHICLES

**លេខកូដ : PW03-R1-17**

**ខ្លឹមសារ** : សញ្ញានេះ ហាមចូលចំពោះយានយន្តគ្រប់ប្រភេទ ។

---



**ហាមចូលចំពោះ ទោចក្រយាន**

NO ENTRY FOR BICYCLE

**លេខកូដ : PW03-R1-18**

**ខ្លឹមសារ** : សញ្ញានេះ ហាមចូលចំពោះទោចក្រយាន ។

---



**ហាមចត**

NO PARKING

**លេខកូដ : PW03-R1-19**

**ខ្លឹមសារ** : សញ្ញានេះ ហាមចត ចំពោះយានជំនិះគ្រប់ប្រភេទ, បុន្តែអ្នកបើកបរអាចឈប់ដាក់មនុស្ស ឬ ទំនិញ ឡើងចុះ ក្នុងរយៈពេលចាំបាច់ ។

---



**ហាមឈប់**

NO STOPPING

**លេខកូដ : PW03-R1-20**

**ខ្លឹមសារ** : សញ្ញានេះ ហាមឈប់ ចំពោះយានជំនិះគ្រប់ប្រភេទ ។

### ហាមចតចាប់ពីថ្ងៃទី ១ ដល់ថ្ងៃទី ១៥




NO PARKING FROM 1st TO 15th OF MONTH

**លេខកូដ : PW03-R1-21**

**ខ្លឹមសារ :** សញ្ញានេះ ហាមចត ចំពោះយានជំនិះគ្រប់ប្រភេទ ចាប់ពីថ្ងៃទី១ ដល់ ថ្ងៃទី១៥ នៃខែនិមួយៗ ប៉ុន្តែអ្នកបើកបរអាចឈប់ដាក់មនុស្ស ឬ ទំនិញឡើងចុះ ក្នុងរយៈពេលចាំបាច់ ។ ការផ្លាស់ប្តូររវាង ថ្ងៃទី១៥ ទៅ ថ្ងៃទី១៦ ប្រព្រឹត្តទៅនៅចន្លោះម៉ោង ២១:០០ ទៅ ២១:៣០ ។

---

### ហាមចតចាប់ពីថ្ងៃទី ១៦ ដល់ថ្ងៃទី ៣១




NO PARKING FROM 16th TO 31st OF MONTH

**លេខកូដ : PW03-R1-22**

**ខ្លឹមសារ :** សញ្ញានេះ ហាមចត ចំពោះយានជំនិះគ្រប់ប្រភេទ ចាប់ពីថ្ងៃទី១៦ ដល់ ថ្ងៃដាច់ខែ នៃខែនិមួយៗ ប៉ុន្តែអ្នកបើកបរអាចឈប់ដាក់មនុស្ស ឬ ទំនិញឡើងចុះ ក្នុងរយៈពេលចាំបាច់ ។ ការផ្លាស់ប្តូររវាង ថ្ងៃដាច់ខែ ទៅ ថ្ងៃទី១ នៃខែបន្ទាប់ ប្រព្រឹត្តទៅនៅចន្លោះម៉ោង ២១:០០ ទៅ ២១:៣០ ។

---

### ហាមចតថ្ងៃសេស




NO PARKING ON ODD DAYS

**លេខកូដ : PW03-R1-23**

**ខ្លឹមសារ :** សញ្ញានេះ ហាមចត ចំពោះយានជំនិះគ្រប់ប្រភេទ នៅថ្ងៃសេស នៃខែនិមួយៗ ប៉ុន្តែអ្នកបើកបរអាច ឈប់ដាក់មនុស្ស ឬ ទំនិញឡើងចុះក្នុងរយៈពេលចាំបាច់ ។ ការផ្លាស់ប្តូររវាង ថ្ងៃសេស ទៅថ្ងៃគត់គូ ប្រព្រឹត្តទៅនៅចន្លោះម៉ោង ២១:០០ ទៅ ២១:៣០ ។

---

### ហាមចតថ្ងៃគត់គូ




NO PARKING ON EVEN DAYS

**លេខកូដ : PW03-R1-24**

**ខ្លឹមសារ :** សញ្ញានេះ ហាមចត ចំពោះយានជំនិះគ្រប់ប្រភេទ នៅថ្ងៃគត់គូ នៃខែនិមួយៗ ប៉ុន្តែអ្នកបើកបរអាច ឈប់ដាក់មនុស្ស ឬ ទំនិញឡើងចុះក្នុងរយៈពេលចាំបាច់ ។ ការផ្លាស់ប្តូររវាង ថ្ងៃគត់គូរ ទៅថ្ងៃសេស ប្រព្រឹត្តទៅនៅចន្លោះម៉ោង ២១:០០ ទៅ ២១:៣០ ។



## ហាមជែង

NO OVERTAKE

**លេខកូដ ៖** **PW03-R1-25**

**ខ្លឹមសារ ៖** សញ្ញានេះ ហាមជែង ចំពោះរថយន្តគ្រប់ប្រភេទ លើកលែងតែទោចក្រយានយន្ត។

---



## ចប់ការហាមជែង

END OF NO OVERTAKING

**លេខកូដ ៖** **PW03-R1-26**

**ខ្លឹមសារ ៖** សញ្ញានេះ ចប់ការហាមជែង ចំពោះយានយន្ត គ្រប់ប្រភេទ។

---



## ហាមជែងចំពោះរថយន្តដឹកទំនិញធុនធំ

NO OVERTAKING FOR LARGE-SIZE TRUCK

**លេខកូដ ៖** **PW03-R1-27**

**ខ្លឹមសារ ៖** សញ្ញានេះ ហាមជែង ចំពោះរថយន្តដឹកទំនិញធុនធំដែល មានទម្ងន់សរុបលើស 3.5តោន។

---



## ចប់ការហាមជែងចំពោះរថយន្តដឹកទំនិញធុនធំ

END OF NO OVERTAKING FOR LARGE-SIZE TRUCK

**លេខកូដ ៖** **PW03-R1-28**

**ខ្លឹមសារ ៖** សញ្ញានេះ ចប់ការហាមជែង ចំពោះរថយន្តដឹកទំនិញធុនធំ ដែលមានទម្ងន់សរុបលើស 3.5តោន។



## ហាមជែង ចំពោះរថយន្តដឹកទំនិញធុនធំ ប្រហាក់ប្រហែលគ្នា

NO OVERTAKE FOR SIMILAR LARGE-SIZE TRUCK

**លេខកូដ ៖** **PW03-R1-29**

**ខ្លឹមសារ ៖** សញ្ញានេះ ហាមជែង ចំពោះរថយន្តដឹកទំនិញធុនធំដែលមានទំហំប្រហាក់ប្រហែលគ្នា។

---



## ចប់ការហាមជែង ចំពោះរថយន្តដឹកទំនិញធុនធំ ប្រហាក់ប្រហែលគ្នា

END OF NO OVERTAKE FOR SIMILAR LARGE-SIZE TRUCK

**លេខកូដ ៖** **PW03-R1-30**

**ខ្លឹមសារ ៖** សញ្ញានេះ ចប់ការហាមជែង ចំពោះរថយន្តដឹកទំនិញធុនធំដែលមានទំហំប្រហាក់ប្រហែលគ្នា។

---



## ហាមស៊ីផ្លេ

NO HORN

**លេខកូដ ៖** **PW03-R1-31**

**ខ្លឹមសារ ៖** សញ្ញានេះ ហាមស៊ីផ្លេ ចំពោះយានជំនិះគ្រប់ប្រភេទ លើកលែងតែករណីអាចមានគ្រោះថ្នាក់បន្ទាន់។

---



## ចប់ការហាមស៊ីផ្លេ

END OF NO HORN

**លេខកូដ ៖** **PW03-R1-32**

**ខ្លឹមសារ ៖** សញ្ញានេះ ចប់ការហាមស៊ីផ្លេ ចំពោះយានជំនិះគ្រប់ប្រភេទ។



**ហាមចូលចំពោះទោចក្រយានយន្តមានសណ្តោង**

NO ENTRY FOR MOTORCYCLE DRAWN VEHICLES

**លេខកូដ : PW03-R1-33**

**ខ្លឹមសារ :** សញ្ញានេះ ហាមចូលចំពោះទោចក្រយានយន្ត ដែលមានសណ្តោងរ៉ឺម៉ក ឬ រទេះ ។



**ហាមចូលចំពោះរទេះអូសទាញដោយសត្វ**

NO ENTRY FOR ANIMAL DRAWN VEHICLES

**លេខកូដ : PW03-R1-34**

**ខ្លឹមសារ :** សញ្ញានេះ ហាមចូលចំពោះរទេះ ដែលអូសទាញដោយសត្វ ។



**ហាមអូស ឬ រុញរទេះចូល**

NO ENTRY FOR HAND-CARTS

**លេខកូដ : PW03-R1-35**

**ខ្លឹមសារ :** សញ្ញានេះ ហាមអូស ឬ រុញរទេះចូល ។



**ហាមចូលចំពោះ យានយន្តកសិកម្ម**

NO ENTRY FOR AGRICULTURAL MOTOR VEHICLES

**លេខកូដ : PW03-R1-36**

**ខ្លឹមសារ :** សញ្ញានេះ ហាមចូលចំពោះយានយន្តកសិកម្មគ្រប់ប្រភេទ ។



## ហាមចូលចំពោះរថយន្តដឹកទំនិញធុនធំមានសណ្តោង

NO ENTRY FOR COMBINATION VEHICLES

**លេខកូដ ៖ PW03-R1-37**

**ខ្លឹមសារ ៖** សញ្ញានេះ ហាមចូល ចំពោះរថយន្តដឹកទំនិញធុនធំ ដែលមានសណ្តោង។

---




## ហាមទុកចន្លោះសុវត្ថិភាព តិចជាង ៧0 ម៉ែត្រ រវាងរថយន្តធុនតូច

DO NOT KEEP SAFETY DISTANCE LESS THAN 70m FOR PASSENGER CARS

**លេខកូដ ៖ PW03-R1-38**

**ខ្លឹមសារ ៖** សញ្ញានេះ ហាមអ្នកបើកបររថយន្តធុនតូច ទុកចន្លោះ សុវត្ថិភាពតិចជាងចម្ងាយ ដូចមានកំណត់ក្នុងផ្លាក សញ្ញា។

---




## ហាមទុកចន្លោះសុវត្ថិភាព តិចជាង ១00 ម៉ែត្រ រវាងរថយន្តធុនធំ

DO NOT KEEP SAFETY DISTANCE LESS THAN 100m FOR TRUCKS

**លេខកូដ ៖ PW03-R1-39**

**ខ្លឹមសារ ៖** សញ្ញានេះ ហាមអ្នកបើកបររថយន្តធុនធំ ទុកចន្លោះ សុវត្ថិភាពតិចជាងចម្ងាយ ដូចមានកំណត់ក្នុងផ្លាក សញ្ញា។

---



## ហាមចូលចំពោះយានយន្តដឹកផលិតផលផ្ទុះ ឬងាយឆេះ

NO ENTRY FOR VEHICLE LOADING INFLAMABLE OR EXPLOSABLE GOODS

**លេខកូដ ៖ PW03-R1-40**

**ខ្លឹមសារ ៖** សញ្ញានេះ ហាមចូលចំពោះយានយន្តដឹកផលិតផល ផ្ទុះ ឬងាយឆេះ។




**កំណត់ល្បឿនអតិបរិមា**

MAXIMUM SPEED LIMIT

**លេខកូដ : PW03-R1-41**

**ខ្លឹមសារ** : សញ្ញានេះ ហាមយានយន្តគ្រប់ប្រភេទ បើកបរលើសល្បឿន (គិតជាគីឡូម៉ែត្រក្នុង១ម៉ោង ) ដូចមានកំណត់ក្នុងផ្លាកសញ្ញា ។

---




**ចប់ការ កំណត់ល្បឿនអតិបរិមា**

END OF MAXIMUM SPEED LIMIT

**លេខកូដ : PW03-R1-42**

**ខ្លឹមសារ** : សញ្ញានេះ ចប់ការហាមចំពោះយានយន្តគ្រប់ប្រភេទ បើកបរលើសល្បឿន ដូចមានកំណត់ក្នុងផ្លាកសញ្ញា ។

---




**ឈប់នៅទីស្នាក់ការគយ**

STOP AT THE CUSTOMS STATION

**លេខកូដ : PW03-R1-43**

**ខ្លឹមសារ** : សញ្ញានេះ តំរូវអោយយានជំនិះគ្រប់ប្រភេទ ឈប់នៅទីស្នាក់ការគយ ដើម្បីធ្វើការត្រួតពិនិត្យ និង បំពេញបែបបទ ។

---




**ឈប់នៅទីស្នាក់ការប៉ូលីស**

STOP AT THE POLICE STATION

**លេខកូដ : PW03-R1-44**

**ខ្លឹមសារ** : សញ្ញានេះ តំរូវអោយយានជំនិះស៊ីវិល គ្រប់ប្រភេទ ឈប់នៅ ទីស្នាក់ការនគរបាលដើម្បីធ្វើការត្រួតពិនិត្យ ។




**ឈប់នៅទីស្នាក់ការអាវុធហត្ថ**

STOP AT THE MILITARY POLICE STATION

**លេខកូដ : PW03-R1-45**

**ខ្លឹមសារ :** សញ្ញានេះ តំរូវអោយយានជំនិះ គ្រប់ប្រភេទ របស់កងកំលាំងប្រដាប់អាវុធ ឈប់នៅទីស្នាក់ការ អាវុធហត្ថ ដើម្បីធ្វើការត្រួតពិនិត្យ ។

# ផ្នែកទី I ( ii )

# ផ្លាកសញ្ញាបញ្ជា

## Mandatory signs

ផ្លាកសញ្ញាបញ្ជាមានរាងមូលមានជាយពណ៌សពទ្ធ័ជុំវិញ មានផ្ទៃពណ៌ខៀវ រូបឬសញ្ញាសំគាល់ខាងក្នុងពណ៌ស ។ ផ្លាកសញ្ញាប្រភេទនេះមានន័យ តំរូវអោយអ្នកបើកបរធ្វើចលនាទៅតាមអត្ថន័យបញ្ជារបស់ សញ្ញានិមួយៗ ដូចជា តំរូវបត់ស្តាំ តំរូវបត់ឆ្វេង.... ។ល។ ក្នុងគោលបំណងជៀសវាងគ្រោះថ្នាក់ ឬកកស្ទះចរាចរនៅតាមផ្លូវ ។

ក្នុងករណីខ្លះត្រូវប្រើផ្លាកសញ្ញា " ចប់បញ្ជា " ដែលមានទ្រង់ទ្រាយដូចគ្នា តែមានឆ្នូតពណ៌ក្រហមកាត់បញ្ឆិតពីឆ្វេងឡើងទៅស្តាំ ។

# ផ្នែកទី I ( ii ) : ផ្លាកសញ្ញាបញ្ជា ( Mandatory Signs )



**តំរូវខាងស្តាំ**

KEEP RIGHT

**លេខកូដ : PW03-R2-01**

**ខ្លឹមសារ :** សញ្ញានេះ តំរូវអោយយានជំនិះគ្រប់ប្រភេទ បើកបរងាក ឬ វាងទៅស្តាំ ។

---



**តំរូវខាងឆ្វេង**

KEEP LEFT

**លេខកូដ : PW03-R2-02**

**ខ្លឹមសារ :** សញ្ញានេះ តំរូវអោយយានជំនិះគ្រប់ប្រភេទ បើកបរ ងាក ឬ វាងទៅឆ្វេង ។

---



**តំរូវបត់ស្តាំ នៅខាងមុខ**

TURN RIGHT AHEAD

**លេខកូដ : PW03-R2-03**

**ខ្លឹមសារ :** សញ្ញានេះ តំរូវអោយយានជំនិះគ្រប់ប្រភេទ បត់ស្តាំ នៅត្រង់ផ្លូវប្រសព្វខាងមុខ ពីក្រោយផ្លាកសញ្ញា ។

---



**តំរូវបត់ឆ្វេង នៅខាងមុខ**

TURN LEFT AHEAD

**លេខកូដ : PW03-R2-04**

**ខ្លឹមសារ :** សញ្ញានេះ តំរូវអោយយានជំនិះគ្រប់ប្រភេទ បត់ឆ្វេង នៅត្រង់ផ្លូវប្រសព្វខាងមុខ ពីក្រោយផ្លាកសញ្ញា ។



**តំរូវទៅមុខត្រង់ ឬ បត់ស្តាំ**

GO STRAIGHT THROUGH OR TURN RIGHT

**លេខកូដ : PW03-R2-05**

**ខ្លឹមសារ :** សញ្ញានេះ តំរូវអោយយានជំនិះគ្រប់ប្រភេទធ្វើចរាចរ ទៅមុខត្រង់ ឬ បត់ស្តាំ នៅត្រង់ផ្លូវប្រសព្វខាងមុខ ។

---



**តំរូវទៅមុខត្រង់ ឬ បត់ឆ្វេង**

GO STRAIGHT THROUGH OR TURN LEFT

**លេខកូដ : PW03-R2-06**

**ខ្លឹមសារ :** សញ្ញានេះ តំរូវអោយយានជំនិះគ្រប់ប្រភេទធ្វើចរាចរ ទៅមុខត្រង់ ឬ បត់ឆ្វេង នៅត្រង់ផ្លូវប្រសព្វខាងមុខ ។

---



**តំរូវបត់ស្តាំ**

TURN RIGHT

**លេខកូដ : PW03-R2-07**

**ខ្លឹមសារ :** សញ្ញានេះ តំរូវអោយយានជំនិះគ្រប់ប្រភេទ បត់ស្តាំ នៅខាងមុខផ្លាកសញ្ញា ។

---



**តំរូវបត់ឆ្វេង**

TURN LEFT

**លេខកូដ : PW03-R2-08**

**ខ្លឹមសារ :** សញ្ញានេះ តំរូវអោយយានជំនិះគ្រប់ប្រភេទ បត់ឆ្វេង នៅខាងមុខផ្លាកសញ្ញា ។



**តំរូវបត់ស្តាំ ឬ បត់ឆ្វេង**

TURN RIGHT OR LEFT

**លេខកូដ : PW03-R2-09**

**ខ្លឹមសារ :** សញ្ញានេះ តំរូវអោយយានជំនិះគ្រប់ប្រភេទ បត់ស្តាំ ឬ បត់ឆ្វេង នៅត្រង់ផ្លូវប្រសព្វខាងមុខ ។

---



**តំរូវទៅមុខត្រង់**

STRAIGHT THROUGH ONLY

**លេខកូដ : PW03-R2-10**

**ខ្លឹមសារ :** សញ្ញានេះ តំរូវអោយយានជំនិះគ្រប់ប្រភេទ ធ្វើចរាចរ ទៅមុខត្រង់ នៅត្រង់ផ្លូវប្រសព្វខាងមុខ ។

---



**ផ្លូវសំរាប់រថយន្តដឹកអ្នកដំណើរ និង រថយន្តធុនតូច**

COMPULSORY BUSES AND PASSENGER CARS

**លេខកូដ : PW03-R2-11**

**ខ្លឹមសារ :** សញ្ញានេះ តំរូវអោយរថយន្តដឹកអ្នកដំណើរ និងរថយន្តធុនតូចធ្វើចរាចរ លើកលែងតែរថយន្តធ្វើអាជីវកម្មដឹកទំនិញ ធុនតូច និង ធុនធំ ។

---



**ផ្លូវសំរាប់រទេះអូសទាញដោយសត្វ**

ANIMAL DRAWN VEHICLE CARTS OF ALL FORM

**លេខកូដ : PW03-R2-12**

**ខ្លឹមសារ :** សញ្ញានេះ តំរូវសំរាប់តែ រទេះអូសទាញដោយសត្វ ធ្វើចរាចរ ដូចជា រទេះគោ រទេះក្របី រទេះសេះ ។



**ផ្លូវសំរាប់ថ្មើរជើង**

COMPULSORY FOOT- PATH

**លេខកូដ : PW03-R2-13**

**ខ្លឹមសារ** : សញ្ញានេះ តំរូវសំរាប់តែ ថ្មើរជើង ធ្វើចរាចរ ។

---



**ចប់ ផ្លូវសំរាប់ថ្មើរជើង**

END OF COMPULSORY FOOT- PATH

**លេខកូដ : PW03-R2-14**

**ខ្លឹមសារ** : សញ្ញានេះ សំរាប់បញ្ចប់ផ្លូវ ថ្មើរជើង ។

---



**ផ្លូវសំរាប់ថ្មើរជើង និង ទោចក្រយាន**

COMPULSORY FOOT- PATH AND BICYCLE TRACK

**លេខកូដ : PW03-R2-15**

**ខ្លឹមសារ** : សញ្ញានេះ តំរូវសំរាប់តែ ថ្មើរជើង និង ទោចក្រយាន ធ្វើចរាចរ ។

---



**ចប់ ផ្លូវសំរាប់ថ្មើរជើង និង ទោចក្រយាន**

END OF COMPULSORY FOOT- PATH
AND BICYCLE TRACK

**លេខកូដ : PW03-R2-16**

**ខ្លឹមសារ** : សញ្ញានេះ សំរាប់បញ្ចប់ផ្លូវថ្មើរជើង និង ទោចក្រយាន ធ្វើចរាចរ ។




**កំណត់ល្បឿនអប្បបរមា**

MINIMUM SPEED LIMIT

**លេខកូដ : PW03-R2-17**

**ខ្លឹមសារ :** សញ្ញានេះ តំរូវអោយយានជំនិះគ្រប់ប្រភេទ បើកបរ ក្នុងល្បឿន (គីឡូម៉ែត្រក្នុង១ម៉ោង )តិចជាង ដូចមាន កំណត់ក្នុងផ្លាកសញ្ញា ។

---




**ចប់ ការកំណត់ល្បឿនអប្បបរមា**

END OF MINIMUM SPEED LIMIT

**លេខកូដ : PW03-R2-18**

**ខ្លឹមសារ :** សញ្ញានេះ សំរាប់បញ្ចប់ ការកំណត់ល្បឿនអប្បបរមា ដូចមានកំណត់ក្នុងផ្លាកសញ្ញា។

---



**ផ្លូវសំរាប់រថយន្តដឹកអ្នកដំណើរ**

COMPULSORY LARGE-SIZE BUS

**លេខកូដ : PW03-R2-19**

**ខ្លឹមសារ :** សញ្ញានេះ តំរូវសំរាប់តែ រថយន្តដឹកអ្នកដំណើរ ធ្វើចរាចរ ។

---



**ចប់ ផ្លូវសំរាប់រថយន្តដឹកអ្នកដំណើរ**

END OF COMPULSORY LARGE-SIZE BUS

**លេខកូដ : PW03-R2-20**

**ខ្លឹមសារ :** សញ្ញានេះសំរាប់បញ្ចប់ ផ្លូវសំរាប់រថយន្តដឹកអ្នកដំណើរ ធ្វើចរាចរ។



**ផ្លូវសំរាប់ទោចក្រយាន**

COMPULSORY BICYCLE TRACK

**លេខកូដ : PW03-R2-21**

**ខ្លឹមសារ** : សញ្ញានេះ តំរូវសំរាប់តែ ទោចក្រយានធ្វើចរាចរ ។

---



**ចប់ ផ្លូវសំរាប់ទោចក្រយាន**

END OF COMPULSORY BICYCLE TRACK

**លេខកូដ : PW03-R2-22**

**ខ្លឹមសារ** : សញ្ញានេះ សំរាប់បញ្ចប់ផ្លូវ ទោចក្រយាន ធ្វើចរាចរ ។

---




**ប្រកាន់ស្តាំ**

KEEP RIGHT

**លេខកូដ : PW03-R2-23**

**ខ្លឹមសារ** : សញ្ញានេះ តំរូវសំរាប់អោយអ្នកបើកបរ យានជំនិះ គ្រប់ប្រភេទ ធ្វើចរាចរ ប្រកាន់ខាងស្តាំ ។

---




**បន្ថយល្បឿន**

SLOW DOWN

**លេខកូដ : PW03-R2-24**

**ខ្លឹមសារ** : សញ្ញានេះ តំរូវសំរាប់អោយអ្នកបើកបរ យានជំនិះ គ្រប់ប្រភេទ បន្ថយល្បឿន ។

# ផ្នែកទី I ( iii )

# ផ្លាកសញ្ញាបង្ហាញសិទ្ធិអាទិភាព

## Priority Signs

ផ្លាកសញ្ញាបង្ហាញពីសិទ្ធិអាទិភាព មានទ្រង់ទ្រាយផ្សេងៗគ្នា ទៅតាមប្រភេទសញ្ញានិមួយៗ ដូចជាសញ្ញា " **ឈប់** " (STOP) មានរាងជាអដ្ឋកោណនិយត័ ដែលមានជាយពណ៌សពទ្ធ័ជុំវិញ ផ្ទៃពណ៌ក្រហម អក្សរពណ៌ស ។ សញ្ញា " **ផ្តល់សិទ្ធិអាទិភាពអោយគេ** " (GIVE WAY) មានរាងជាត្រីកោណសមង្ស័ ដែលមានកំពូលមួយចុះក្រោម មានស៊ុំពីរជាន់ ស៊ុំខាងក្រៅពណ៌សហើយស្តើង ឯស៊ុំខាងក្នុងពណ៌ក្រហមហើយក្រាស់ និងផ្ទៃខាងក្នុងពណ៌ស... ។ល។

ផ្លាកសញ្ញាប្រភេទនេះសំរាប់ប្រាប់អ្នកបើកបរអោយបានដឹងពី សិទ្ធិអាទិភាពរបស់ខ្លួន នៅពេលមានផ្លូវតូចចង្អៀត ផ្លូវប្រសព្វ ឬ ផ្លូវរថភ្លើងឆ្លងកាត់ ។

# ផ្នែកទី I ( iii ) : ផ្លាកសញ្ញាបង្ហាញសិទ្ធិអាទិភាព ( Priority Signs )




**ឈប់ (នៅត្រង់ផ្លូវប្រសព្វ)**

STOP ( at Intersection )

**លេខកូដ : PW03-R3-01**

**ខ្លឹមសារ :** សញ្ញានេះ សំរាប់សំគាល់ផ្លូវបាត់សិទ្ធិ ។ អ្នកបើកបរត្រូវឈប់ទោះបីមាន ឬ គ្មានយានជំនិះផ្សេងទៀត ឆ្លងកាត់នៅខាងមុខក៏ដោយ។ អ្នកបើកបរអាចបន្តដំណើរទៅមុខបានលុះត្រាតែផ្លូវដែលត្រូវឆ្លងកាត់នោះទំនេរ។

---



**ផ្តល់សិទ្ធិអាទិភាពអោយគេ (នៅត្រង់ផ្លូវប្រសព្វ)**

GIVE WAY ( at Intersection )

**លេខកូដ : PW03-R3-02**

**ខ្លឹមសារ :** សញ្ញានេះ សំរាប់សំគាល់ផ្លូវបាត់សិទ្ធិ ។ អ្នកបើកបរត្រូវតែបន្ថយល្បឿន បើសិនផ្លូវទំនេរ អាចឆ្លងកាត់បាន ។ បើផ្លូវមិនទំនេរ អ្នកបើកបរត្រូវឈប់រង់ចាំរហូត ដល់ផ្លូវទំនេរ ទើបអាចបន្តដំណើរបាន ។

---



**ផ្តល់សិទ្ធិអាទិភាពអោយគេ ( នៅរង្វង់មូល )**

GIVE WAY ( at Roundabout )

**លេខកូដ : PW03-R3-03**

**ខ្លឹមសារ :** សញ្ញានេះ សំរាប់សំគាល់ផ្លូវបាត់សិទ្ធិ ។ អ្នកបើកបរត្រូវតែបន្ថយល្បឿន ឬ ឈប់ ដើម្បីផ្តល់សិទ្ធិអោយយាននៅក្នុងផ្លូវរង្វង់មូលទៅមុន ។

---



**ផ្លូវធំមានសិទ្ធិ**

PRIORITY ROAD ( PRIORITY AT THE FIRST JUNCTION )

**លេខកូដ : PW03-R3-04**

**ខ្លឹមសារ :** សញ្ញានេះ សំរាប់សំគាល់ផ្លូវធំ មានផ្លូវតូចឆ្លងកាត់នៅខាងមុខ ។



**ផ្លូវសំខាន់មានសិទ្ធិ**

MAIN ROAD

**លេខកូដ : PW03-R3-05**

**ខ្លឹមសារ :** សញ្ញានេះ សំរាប់សំគាល់ផ្លូវសំខាន់ មានសិទ្ធិអាទិភាព លើផ្លូវច្រើនដែលត្រូវឆ្លងកាត់នៅខាងមុខ ។

---



**ចប់ ផ្លូវសំខាន់មានសិទ្ធិ**

END OF MAIN ROAD

**លេខកូដ : PW03-R3-06**

**ខ្លឹមសារ :** សញ្ញានេះ សំរាប់ បញ្ចប់ផ្លូវសំខាន់មានសិទ្ធិ ។

---



**ផ្តល់សិទ្ធិអាទិភាពអោយយានមកពីទិសផ្ទុយ**

GIVE WAY TO ALL TRAFFIC FROM
THE OPPOSITE DIRECTION

**លេខកូដ : PW03-R3-07**

**ខ្លឹមសារ :** សញ្ញានេះ សំរាប់សំគាល់ផ្លូវធំ រួមតូច នៅខាងមុខអាចធ្វើចរាចរបានតែមួយជួរ ។ អ្នកបើកបរលើកំណាត់ផ្លូវដែលមានសញ្ញានេះ ត្រូវផ្តល់សិទ្ធិអាទិភាព អោយយាន មកពីទិសផ្ទុយទៅមុន ។

---



**មានសិទ្ធិអាទិភាពលើយានមកពីទិសផ្ទុយ**

PRIORITY OVER ALL TRAFFIC FROM
THE OPPOSITE DIRECTION

**លេខកូដ : PW03-R3-08**

**ខ្លឹមសារ :** សញ្ញានេះ សំរាប់សំគាល់ផ្លូវធំ រួមតូច នៅខាងមុខអាចធ្វើចរាចរបានតែមួយជួរ ។ អ្នកបើកបរលើកំណាត់ផ្លូវដែលមានសញ្ញានេះ មានសិទ្ធិអាទិភាព លើយានមកពីទិសផ្ទុយ ។



**មានផ្លូវរថភ្លើងឆ្លងកាត់ ( មួយខ្សែ )**

RAILWAY CROSSING ( ONE TRACK )

**លេខកូដ : PW03-R3-09**

**ខ្លឹមសារ :** សញ្ញានេះ សំរាប់សំគាល់ មានផ្លូវរថភ្លើងចំនួនមួយខ្សែឆ្លងកាត់នៅខាងមុខ ។ អ្នកបើកបរត្រូវទុកសិទ្ធិអាទិភាព អោយរថភ្លើងឆ្លងកាត់មុន ។

---



**មានផ្លូវរថភ្លើងឆ្លងកាត់ ( ពីរឬច្រើនខ្សែ )**

RAILWAY CROSSING ( TWO OR MORE TRACKS )

**លេខកូដ : PW03-R3-10**

**ខ្លឹមសារ :** សញ្ញានេះ សំរាប់សំគាល់ មានផ្លូវរថភ្លើងចំនួនពីរ ឬ ច្រើនខ្សែ ឆ្លងកាត់នៅខាងមុខ។ អ្នកបើកបរត្រូវទុកសិទ្ធិអាទិភាព អោយរថភ្លើងឆ្លងកាត់មុន។

# ផ្នែកទី II ( i )

# ផ្លាកសញ្ញាគ្រោះថ្នាក់

# Warning Signs

ផ្លាកសញ្ញាគ្រោះថ្នាក់មានរាងជាការេ ដែលមានអង្កត់ទ្រូងមួយជាខ្សែឈរ និងអង្កត់ទ្រូងមួយទៀតជាខ្សែដេក មានជាយក្នុងពណ៌ខ្មៅ និង ជាយក្រៅពណ៌ស ផ្ទៃពណ៌លឿង រូប ឬ សញ្ញាសំគាល់ ខាងក្នុងពណ៌ខ្មៅ ។

គឺជាប្រភេទសញ្ញា សំរាប់ពញ្ញាក់អារម្មណ៍អ្នកបើកបរ អោយបង្កើនការប្រុងប្រយ័ត្នពិសេស ថែមទៀត ដើម្បី ជៀសវាងគ្រោះថ្នាក់ ដែលអាចកើតមានឡើងជាយថាហេតុ ។ បើឃើញផ្លាកសញ្ញានេះ អ្នកបើកបរ ត្រូវ បន្ថយល្បឿន និង អនុវត្តតាមខ្លឹមសារ នៃសញ្ញានេះជាដាច់ខាត ។

# ផ្នែកទី II ( i ) : ផ្លាកសញ្ញាគ្រោះថ្នាក់ ( Warning Signs )



## គ្រោះថ្នាក់ផ្សេងៗ

DENGERS

**លេខកូដ : PW03-W1-01**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់បញ្ជាក់អំពី គ្រោះថ្នាក់ផ្សេងៗ ដែលគ្មានចែងនៅក្នុងប្រភេទសញ្ញាគ្រោះថ្នាក់ ។ នៅក្រោមសញ្ញានេះត្រូវសរសេរបញ្ជាក់ប្រភេទគ្រោះថ្នាក់ ដូចជាច្រកចេញចូលរោងចក្រ ឬដើមឈើទ្រេត ។ល។

---



## ផ្លូវកោងទៅស្តាំ

RIGHT BEND

**លេខកូដ : PW03-W1-02**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ប្រុងប្រយ័ត្ន មានផ្លូវកោង ទៅស្តាំ នៅខាងមុខ ។

---



## ផ្លូវកោងទៅឆ្វេង

LEFT BEND

**លេខកូដ : PW03-W1-03**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ប្រុងប្រយ័ត្ន មានផ្លូវកោង ទៅឆ្វេង នៅខាងមុខ ។

---



## ផ្លូវកោងគ្រោះថ្នាក់ ( កោងទៅស្តាំ ហើយទៅឆ្វេង )

DOUBLE BEND TO RIGHT AND TO LEFT

**លេខកូដ : PW03-W1-04**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរប្រុងប្រយ័ត្នមានផ្លូវកោងទៅស្តាំ ហើយកោងទៅឆ្វេង នៅខាងមុខ ។



**II . 24 ផ្លូវកោងគ្រោះថ្នាក់ ( កោងទៅឆ្វេង ហើយទៅស្តាំ )**

DOUBLE BEND TO LEFT AND TO RIGHT

**លេខកូដ : PW03-W1-05**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរប្រុងប្រយត្ន័មាន ផ្លូវកោងទៅឆ្វេង ហើយកោងទៅស្តាំ នៅខាងមុខ ។

---



**ផ្លូវកោងបត់បែន**

WINDING ROAD

**លេខកូដ : PW03-W1-06**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ប្រុងប្រយត្ន័ មានផ្លូវកោងបត់បែនច្រើនសារ នៅខាងមុខ ។

---



**មានផ្លូវបំបែកទៅខាងស្តាំ**

ROAD JUNCTION ON THE RIGHT

**លេខកូដ : PW03-W1-07**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ប្រុងប្រយត្ន័ មានផ្លូវបំបែកទៅខាងស្តាំ នៅខាងមុខ ។

---



**មានផ្លូវបំបែកទៅខាងឆ្វេង**

ROAD JUNCTION ON THE LEFT

**លេខកូដ : PW03-W1-08**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ប្រុងប្រយត្ន័ មានផ្លូវបំបែកទៅខាងឆ្វេង នៅខាងមុខ ។



**ផ្លូវបំបែករាង Y**

Y- INTERSECTION AHEAD

**លេខកូដ : PW03-W1-09**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ប្រុងប្រយ័ត្ន មានផ្លូវបំបែករាង **Y** នៅខាងមុខ ។

---



**ផ្លូវបំបែករាង T**

T- INTERSECTION AHEAD

**លេខកូដ : PW03-W1-10**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ប្រុងប្រយ័ត្ន មានផ្លូវបំបែករាង **T** នៅខាងមុខ ។

---



**ផ្លូវបំបែកកែងនៅខាងឆ្វេង**

ROAD JUNCTION ON THE LEFT

**លេខកូដ : PW03-W1-11**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ប្រុងប្រយ័ត្ន ខាងមុខមានផ្លូវបំបែកកែង នៅខាងឆ្វេង ។

---



**ផ្លូវបំបែកកែងនៅខាងស្តាំ**

ROAD JUNCTION ON THE RIGHT

**លេខកូដ : PW03-W1-12**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ប្រុងប្រយ័ត្ន ខាងមុខមានផ្លូវបំបែកកែង នៅខាងស្តាំ ។



**ផ្លូវបំបែកកែងទៅខាងស្តាំ រួចបំបែកកែងទៅខាងឆ្វេង**

STAGGERED JUNCTION,
RIGHT TURN FIRST

**លេខកូដ : PW03-W1-13**

**ខ្លឹមសារ** : សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ប្រុងប្រយត្ន័ ខាងមុខមានផ្លូវបំបែក កែងទៅខាងស្តាំ រួចបំបែក កែងទៅខាងឆ្វេង ។

---



**ផ្លូវបំបែកកែងទៅខាងឆ្វេង រួចបំបែកកែងទៅខាងស្តាំ**

STAGGERED JUNCTION,
LEFT TURN FIRST

**លេខកូដ : PW03-W1-14**

**ខ្លឹមសារ** : សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ប្រុងប្រយត្ន័ ខាងមុខមានផ្លូវបំបែក កែងទៅខាងឆ្វេង រួចបំបែក កែងទៅខាងស្តាំ ។

---



**ផ្លូវខ្វែង**

CROSS ROAD

**លេខកូដ : PW03-W1-15**

**ខ្លឹមសារ** : សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ប្រុងប្រយត្ន័ ខាងមុខមានផ្លូវខ្វែង ។

---



**រង្វង់មូល**

ROUND ABOUT

**លេខកូដ : PW03-W1-16**

**ខ្លឹមសារ** : សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ប្រុងប្រយត្ន័ ខាងមុខមាន រង្វង់មូល ។



**ផ្លូវមានចរាចរពីរទិស**

TWO-WAY TRAFFIC ZONE

**លេខកូដ : PW03-W1-17**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ប្រុងប្រយ័ត្ន ខាងមុខមាន ផ្លូវដែលធ្វើចរាចរពីរទិស ។

---



**ផ្លូវរួមតូច**

CARRIAGE WAY NARROWS

**លេខកូដ : PW03-W1-18**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ប្រុងប្រយ័ត្ន ខាងមុខមាន ផ្លូវរួមតូច ។

---



**ផ្លូវរួមតូចនៅខាងស្តាំ**

CARRIAGE WAY NARROWS ON RHS

**លេខកូដ : PW03-W1-19**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ប្រុងប្រយ័ត្ន ខាងមុខមាន ផ្លូវរួមតូចនៅខាងស្តាំ ។

---



**ផ្លូវរួមតូចនៅខាងឆ្វេង**

CARRIAGE WAY NARROWS ON LHS

**លេខកូដ : PW03-W1-20**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ប្រុងប្រយ័ត្ន ខាងមុខមាន ផ្លូវរួមតូចនៅខាងឆ្វេង ។

**ផ្លូវកែងបត់ស្តាំ**
SHARP RIGHT TURN



**លេខកូដ : PW03-W1-21**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ប្រុងប្រយ័ត្ន ខាងមុខមាន ផ្លូវកែងបត់ទៅស្តាំ ។

---

**ផ្លូវកែងបត់ឆ្វេង**
SHARP LEFT TURN



**លេខកូដ : PW03-W1-22**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ប្រុងប្រយ័ត្ន ខាងមុខមាន ផ្លូវកែងបត់ទៅឆ្វេង ។

---

**ផ្លូវកែងបត់ស្តាំ រួចកែងបត់ឆ្វេង**
SHARP RIGHT TURN AND LEFT TURN



**លេខកូដ : PW03-W1-23**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ប្រុងប្រយ័ត្ន ខាងមុខមានផ្លូវកែងបត់ស្តាំ រួចកែងបត់ឆ្វេង ។

---

**ផ្លូវកែងបត់ឆ្វេង រួចកែងបត់ស្តាំ**
SHARP LEFT TURN AND RIGHT TURN



**លេខកូដ : PW03-W1-24**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ប្រុងប្រយ័ត្ន ខាងមុខមានផ្លូវកែងបត់ឆ្វេង រួចកែងបត់ស្តាំ ។



### ផ្លូវបត់ស្តាំមានផ្លូវរថភ្លើងឆ្លងកាត់
RAILWAY CROSSING ON RIGHT ROAD

**លេខកូដ : PW03-W1-25**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ប្រុងប្រយត្ន័ ផ្លូវបត់ស្តាំខាងមុខមាន ផ្លូវរថភ្លើងឆ្លងកាត់ ។

---



### ផ្លូវបត់ឆ្វេងមានផ្លូវរថភ្លើងឆ្លងកាត់
RAILWAY CROSSING ON LEFT ROAD

**លេខកូដ : PW03-W1-26**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ប្រុងប្រយត្ន័ ផ្លូវបត់ឆ្វេងខាងមុខមាន ផ្លូវរថភ្លើងឆ្លងកាត់ ។

---



### មានផ្លូវរថភ្លើងឆ្លងកាត់ (មានរបាំង)
RAILWAY CROSSING WITH GATES

**លេខកូដ : PW03-W1-27**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ប្រុងប្រយត្ន័ ខាងមុខមាន ផ្លូវរថភ្លើងឆ្លងកាត់ ដោយមានរបាំងការពារ ។

---



### មានផ្លូវរថភ្លើងឆ្លងកាត់ (គ្មានរបាំង)
RAILWAY CROSSING WITHOUT GATES

**លេខកូដ : PW03-W1-28**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ប្រុងប្រយត្ន័ ខាងមុខមាន ផ្លូវរថភ្លើងឆ្លងកាត់ ដោយគ្មានរបាំងការពារ ។



**ផ្លូវឡើងចំណោត**

STEEP ASCENT

**លេខកូដ : PW03-W1-29**

**ខ្លឹមសារ** : សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ប្រុងប្រយ័ត្ន ខាងមុខមាន ផ្លូវឡើងចំណោត ។

---



**ផ្លូវចុះចំណោត**

STEEP DESCENT

**លេខកូដ : PW03-W1-30**

**ខ្លឹមសារ** : សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ប្រុងប្រយ័ត្ន ខាងមុខមាន ផ្លូវចុះចំណោត ។

---



**ផ្លូវមានទួល**

ROAD HUMP

**លេខកូដ : PW03-W1-31**

**ខ្លឹមសារ** : សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ប្រុងប្រយ័ត្ន ផ្លូវមានទួល នៅខាងមុខ ។

---



**ផ្លូវទឹករលក**

BUMPY ROAD

**លេខកូដ : PW03-W1-32**

**ខ្លឹមសារ** : សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ប្រុងប្រយ័ត្ន ខាងមុខមាន ផ្លូវទឹករលក ។



**មានកុមារឆ្លងកាត់**

CHILDREN CROSSING

**លេខកូដ : PW03-W1-33**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ប្រុងប្រយ័ត្ន ខាងមុខអាចមាន កុមារឆ្លងកាត់ ។

---



**មានថ្មើរជើងឆ្លងកាត់**

PEDESTRIAN CROSSING

**លេខកូដ : PW03-W1-34**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ប្រុងប្រយ័ត្ន ខាងមុខអាចមាន ថ្មើរជើងឆ្លងកាត់ ។

---



**មានមនុស្សពិការឆ្លងកាត់**

DISABLED PEOPLE CROSSING AHEAD

**លេខកូដ : PW03-W1-35**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ប្រុងប្រយ័ត្ន ខាងមុខអាចមាន មនុស្សពិការឆ្លងកាត់ ។

---



**មានសត្វពាហនៈឆ្លងកាត់**

ANIMALS CROSSING

**លេខកូដ : PW03-W1-36**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ប្រុងប្រយ័ត្ន ខាងមុខអាចមាន សត្វពាហនៈឆ្លងកាត់ ។



**មានសត្វព្រៃឆ្លងកាត់**

WILD ANIMALS CROSSING

**លេខកូដ : PW03-W1-37**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ប្រុងប្រយ័ត្ន ខាងមុខអាចមាន សត្វព្រៃឆ្លងកាត់ញឹកញាប់ ។

---



**ផ្លូវរអិល**

SPIPPERY ROAD

**លេខកូដ : PW03-W1-38**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ប្រុងប្រយ័ត្ន ខាងមុខអាចរអិល ពិសេសនៅពេលភ្លៀង ។

---



**មានថ្មធ្លាក់**

FALLING ROCKS

**លេខកូដ : PW03-W1-39**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ប្រុងប្រយ័ត្ន ខាងមុខមាន ថ្មធ្លាក់ ឬ មានដុំថ្មលើទ្រូងផ្លូវ ។

---



**មានថ្មខ្ចាត**

LOOSE STONES

**លេខកូដ : PW03-W1-40**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ប្រុងប្រយ័ត្ន ខាងមុខមាន ដុំថ្មក្រាលលើទ្រូងផ្លូវ ។



**មានខ្យល់បក់ខ្លាំង**

CROSS WIND CAUTION

**លេខកូដ : PW03-W1-41**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ប្រុងប្រយត្ន័ខាងមុខអាចមាន ខ្យល់បក់ខ្លាំង ។

---



**មានភ្លើងសញ្ញាចរាចរ**

TRAFFIC LIGHTS

**លេខកូដ : PW03-W1-42**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ប្រុងប្រយត្ន័នៅខាងមុខមានភ្លើងសញ្ញចរាចរ (ភ្លើងស្តុប )។ សញ្ញានេះប្រើតែក្នុងករណីដែលទីតាំងភូមិសាស្រ្ត ពុំអនុគ្រោះអោយអ្នកបើកបរ មើលឃើញច្បាស់ នូវភ្លើងសញ្ញាចរាចរ ខាងមុខ ។

---



**មានផ្លាកសញ្ញា "ឈប់ "**

STOP SIGN AHEAD

**លេខកូដ : PW03-W1-43**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ប្រុងប្រយត្ន័នៅផ្លូវប្រសព្វខាងមុខ មានផ្លាកសញ្ញា **ឈប់** ។ សញ្ញានេះប្រើតែក្នុងករណី ដែល ទីតាំងភូមិសាស្រ្ត ពុំអនុគ្រោះអោយអ្នក បើកបរ មើលឃើញច្បាស់ នូវផ្លាកសញ្ញា **ឈប់** ខាងមុខ ។

---



**មានផ្លាកសញ្ញា "ផ្តល់សិទ្ធិអាទិភាពអោយគេ"**

GIVE WAY SIGN AHEAD

**លេខកូដ : PW03-W1-44**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ប្រុងប្រយត្ន័នៅផ្លូវប្រសព្វខាងមុខ មានផ្លាកសញ្ញា **ផ្តល់សិទ្ធិអាទិភាពអោយគេ** ។ សញ្ញានេះប្រើតែក្នុងករណី ដែលទីតាំងភូមិសាស្រ្ត ពុំអនុគ្រោះអោយអ្នកបើកបរ មើលឃើញច្បាស់ នូវផ្លាកសញ្ញា **ផ្តល់សិទ្ធិអាទិភាពអោយគេ** ខាងមុខ។



**ទ្រូងផ្លូវបែកជាពីរ**

DEVIDED ROAD

**លេខកូដ : PW03-W1-45**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ប្រុងប្រយត្ន័ ខាងមុខមាន ទ្រូងផ្លូវបែកជាពីរ ។

---



**ចប់ ទ្រូងផ្លូវបែកជាពីរ**

DEVIDED ROAD END

**លេខកូដ : PW03-W1-46**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ប្រុងប្រយត្ន័ ខាងមុខ ចប់ ទ្រូងផ្លូវបែកជាពីរ ។

---



**ផ្លូវមានយន្តហោះ ហោះទាបពីលើ**

LOW FLYING AIR CRAFT

**លេខកូដ : PW03-W1-47**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ប្រុងប្រយត្ន័ ខាងមុខ អាចមានយន្តហោះ ហោះកាត់ញឹកញាប់ យ៉ាងទាបពីលើ ។

---



**ទោចក្រយានឆ្លងកាត់**

BICYCLE CROSSING

**លេខកូដ : PW03-W1-48**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ប្រុងប្រយត្ន័ ខាងមុខ អាចមានទោក្រយានឆ្លងកាត់ ។



**ចុងផ្លូវមាត់ទឹក**

ROAD END OF QUAY SIDE OR RIVER BANK

**លេខកូដ : PW03-W1-49**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ប្រុងប្រយត្ន័ខាងមុខ ជាចុងផ្លូវជាប់ មាត់ទឹក ដូចជា កំពង់ផែ កំពង់ចំលង ។ល។

# ផ្នែកទី II ( ii )

# ផ្លាកសញ្ញាបណ្តោះអាសន្ន

# Temporary Signs

ផ្លាកសញ្ញាបណ្តោះអាសន្ន មានទ្រង់ទ្រាយនិងពណ៌ខុសៗគ្នា ។ ខ្លះរាងជាការេដែលមាន អង្កត់ទ្រូងមួយជាខ្សែឈរ ខ្លះរាងជាចតុកោណកែង ខ្លះរាងជាសាជី ខ្លះទៀតជាទង់ក្រណាត់ ។ល។

ផ្លាកសញ្ញាប្រភេទនេះជាទូទៅច្រើនប្រើ នៅពេលមានការដ្ឋានតាមផ្លូវថ្នល់ សំរាប់ការពារគ្រោះថ្នាក់ដល់កម្មករដែលកំពុងបំពេញភារកិច្ចនៅការដ្ឋាន ក៏ដូចជាអ្នកធ្វើចរាចរតាមផ្លូវដែរ ។ អ្នកបើកបរ ត្រូវតែបង្កើនការប្រុងប្រយត្ន័ អនុវត្តតាមអត្ថន័យរបស់ផ្លាកសញ្ញា ឬ តាមបញ្ជានៃអ្នកទទួលខុសត្រូវនៅកន្លែងនោះ ។



**មានការដ្ឋាន**

ROAD WORKS AHEAD

**លេខកូដ : PW03-W2-01**

**ខ្លឹមសារ** : សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ប្រុងប្រយ័ត្ន មានការដ្ឋាន នៅខាងមុខ ។

---



**ការដ្ឋាន**

ROAD WORKS

**លេខកូដ : PW03-W2-02**

**ខ្លឹមសារ** : សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ប្រុងប្រយ័ត្ន មានការដ្ឋាន ចាប់ផ្ដើមពីផ្លាកសញ្ញានេះទៅ ។

---



**ផ្លូវមានថ្មខ្ចាត**

LOOSE STONES

**លេខកូដ : PW03-W2-03**

**ខ្លឹមសារ** : សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ប្រុងប្រយ័ត្ន មានដុំថ្មក្រាលលើទ្រូងផ្លូវ ចាប់ពីផ្លាកសញ្ញានេះទៅ ។

---




**ចប់ ការដ្ឋាន**

END ROAD WORKS

**លេខកូដ : PW03-W2-04**

**ខ្លឹមសារ** : សញ្ញានេះប្រើសំរាប់អោយដំណឹងដល់អ្នកបើកបរ ពីចុងបញ្ចប់ នៃការដ្ឋាន ។




**ផ្លូវវាងទៅខាងស្តាំ**

DETOUR TO THE RIGHT

**លេខកូដ : PW03-W2-05**

**ខ្លឹមសារ** : សញ្ញានេះ ប្រើសំរាប់បង្ហាញអ្នកបើកបរ អោយវាង តាមសញ្ញាព្រួញ ទៅស្តាំ ។

---




**ផ្លូវវាងទៅខាងឆ្វេង**

DETOUR TO THE LEFT

**លេខកូដ : PW03-W2-06**

**ខ្លឹមសារ** : សញ្ញានេះ ប្រើសំរាប់បង្ហាញអ្នកបើកបរ អោយវាង តាមសញ្ញាព្រួញ ទៅឆ្វេង ។

---



**បង្គោលរាងសាជី**

TRAFFIC CONE

**លេខកូដ : PW03-W2-07**

**ខ្លឹមសារ** : បង្គោលសាជី ប្រើសំរាប់ ធ្វើជារនាំងការពារ បរិវេណការដ្ឋាន ឬ កន្លែងផ្សេងៗ ដែលចាំបាច់ ។

---



**សញ្ញាព្រួញបង្វែរទិស**

DIRECTION TO BE FOLLOWED

**លេខកូដ : PW03-W2-08**

**ខ្លឹមសារ** : សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ប្តូរទិស ទៅតាម មុខព្រួញ នៃផ្ទាកសញ្ញា ។




**សញ្ញាឈប់**

STOP SIGN

**លេខកូដ : PW03-W2-09**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ឈប់នៅពីមុខ ផ្លាកសញ្ញា ដែលកាន់ដោយ ភ្នាក់ងារការដ្ឋាន ។

---



**សញ្ញាបើកផ្លូវ**

GO SIGN

**លេខកូដ : PW03-W2-10**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ បន្តដំណើរ ។

---



រូប ក



រូប ខ

**ទង់ក្រហម**

RED FLAG

**លេខកូដ : PW03-W2-11**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់អោយអ្នកបើកបរ ឈប់នៅមុខ ភ្នាក់ងារការដ្ឋាន ដែលកាន់ទង់ក្រហមសន្ធឹងកាត់ទទឹងថ្នល់ ( រូប ក ) ។ អ្នកបើកបរ អាចបន្តដំណើរបាន លុះត្រាភ្នាក់ងារការដ្ឋាន ដាក់ទង់ក្រហមចុះ ហើយដៃឆ្វេងធ្វើសញ្ញាបញ្ឆ្វារអោយទៅ ( រូប ខ ) ។

# ផ្នែកទី III ( i )

# ផ្លាកសញ្ញាបង្ហាញទិសដៅ

# Direction Signs

ផ្លាកសញ្ញាបង្ហាញទិសដៅមានរាងជាចតុកោណកែង និងមានពណ៌ខុសគ្នា ដែលមានអត្ថន័យដូចតទៅ ៖

- ផ្ទៃពណ៌បៃតង អក្សរនិងព្រួញពណ៌ស សំរាប់ប្រាប់ទិសដៅឆ្ពោះទៅទីក្រុង ឬទីរួមខេត្តសំខាន់ៗ ។
- ផ្ទៃពណ៌បៃតងស៊ីពណ៌លឿង អក្សរពណ៌ស និងព្រួញពណ៌លឿង សំរាប់ប្រាប់ទិសដៅ ឆ្ពោះទៅកន្លែងទេសចរណ៍ ឬតំបន់សំខាន់ៗ ។
- ផ្ទៃពណ៌ស អក្សរនិងព្រួញពណ៌ខ្មៅ សំរាប់ប្រាប់ទិសដៅឆ្ពោះទៅតំបន់ផ្សេងៗ ដូចជាទីរួមស្រុក ឬ ឃុំ ។

# ផ្នែកទី III ( i ) : ផ្លាកសញ្ញាបង្ហាញទិសដៅ ( Direction Signs )




**សញ្ញាបង្ហាញទិសដៅទៅខេត្ត ក្រុង (មានរង្វង់មូល)**

DIRECTION SIGN TO CITIES OR PROVINCES
(AT ROUNDABOUT)

**លេខកូដ : PW03-G1-01**

**ខ្លឹមសារ** : សញ្ញានេះ ប្រើសំរាប់បង្ហាញទិសដៅដល់ អ្នកបើកបរ អោយបានដឹង ពីទិសដៅឆ្ពោះទៅខេត្តក្រុងនៅផ្លូវបំបែក ដែលមានរង្វង់មូល ខាងមុខ ។

---




**សញ្ញាបង្ហាញទិសដៅទៅខេត្ត ក្រុង (គ្មានរង្វង់មូល)**

DIRECTION SIGN TO CITIES OR PROVINCES
(AT JUNCTION)

**លេខកូដ : PW03-G1-02**

**ខ្លឹមសារ** : សញ្ញានេះ ប្រើសំរាប់បង្ហាញទិសដៅដល់ អ្នកបើកបរ អោយបានដឹង ពីទិសដៅឆ្ពោះទៅខេត្តក្រុង នៅផ្លូវបំបែក ខាងមុខ ។

---




**សញ្ញាបង្ហាញទិសដៅទៅតំបន់ផ្សេងៗ (មានរង្វង់មូល)**

DIRECTION SIGN TO OTHER AREAS
(AT ROUNDABOUT)

**លេខកូដ : PW03-G1-03**

**ខ្លឹមសារ** : សញ្ញានេះ ប្រើសំរាប់ បង្ហាញទិសដៅដល់ អ្នកបើកបរ អោយបានដឹងពីទិសដៅឆ្ពោះទៅតំបន់ផ្សេងៗ ដូចជា ទីរួមស្រុក ឬ ឃុំ នៅផ្លូវបំបែកខាងមុខ ។




## សញ្ញាបង្ហាញទិសដៅទៅតំបន់ផ្សេងៗ
**(គ្មានរង្វង់មូល)**

GUIDE SIGN TO OTHER PLACES (AT JUNCTION)

**លេខកូដ ៖ PW03-G1-04**

**ខ្លឹមសារ ៖** សញ្ញានេះ ប្រើសម្រាប់ បង្ហាញទិសដៅដល់ អ្នកបើកបរអោយបានដឹងពីទិសដៅឆ្ពោះទៅ តំបន់ផ្សេងៗ ដូចជាទីរួមស្រុក ឬ ឃុំ នៅផ្លូវ បំបែកខាងមុខ។

---




## សញ្ញាបង្ហាញទិសដៅផ្សេងៗ
GUIDE SIGN TO OTHER PLACES (1)

**លេខកូដ ៖ PW03-G1-05**

**ខ្លឹមសារ ៖** សញ្ញានេះ ត្រូវព្យួរនឹងបង្គោលរបារ លើគន្លងផ្លូវចរាចរប្រើសម្រាប់បង្ហាញទិសដៅ ឆ្ពោះទៅរកផ្លូវ ឬ ទីកន្លែងសំខាន់ៗ។

---

## សញ្ញាបង្ហាញទិសដៅផ្សេងៗ(២)
GUIDE SIGN TO OTHER PLACES (2)




**លេខកូដ ៖ PW03-G1-06**

**ខ្លឹមសារ ៖** សញ្ញានេះ ត្រូវដាក់នៅខាងស្តាំដៃ ប្រើសម្រាប់ បង្ហាញទិសដៅ ឆ្ពោះទៅរកផ្លូវ ឬ ទីកន្លែង សំខាន់ៗ។

# ផ្នែកទី III ( ii )

# ផ្លាកសញ្ញាប្រាប់ ទីប្រជុំជន និង ព្រំប្រទល់តំបន់

## ( Buildup Area and Boundary Signs )

ផ្លាកសញ្ញាប្រាប់ ទីប្រជុំជន មានរាងជាចតុកោណកែង ដែលមានជ្រុងដេកវែងជាងជ្រុងឈរ មានស៊ុំក្រៅពណ៌ស ស៊ុំក្នុងពណ៌ក្រហម ផ្ទៃពណ៌ស និង អក្សរខាងក្នុងដែលជាឈ្មោះរបស់ទីប្រជុំជន ពណ៌ខ្មៅ ។ ផ្លាកសញ្ញាប្រភេទនេះសំរាប់ ប្រាប់អ្នកបើកបរ អោយបានដឹង ពីចំណុចចាប់ផ្តើម នៃទីប្រជុំជន ។ ក្នុងករណីស៊ុំខាងក្នុងប្តូរពីពណ៌ក្រហមទៅជាពណ៌ខ្មៅ និង មានឆ្នូតក្រហមកាត់ ពីកំពូលក្រោមខាងឆ្វេង ទៅកំពូលលើខាងស្តាំ ប្រាប់ពីចំណុច បញ្ចប់ ទីប្រជុំជន ។

សញ្ញាប្រាប់ ព្រំប្រទល់តំបន់ មានរាងជាចតុកោណកែង ដែលមានជ្រុងដេកវែងជាងជ្រុងឈរ ដូចគ្នាដែរ តែមានស៊ុំក្រៅ ពណ៌ស ផ្ទៃពណ៌ខៀវ និង អក្សរខាងក្នុងដែលជាឈ្មោះព្រំប្រទល់ ភូមិ ឃុំ-សង្កាត់ ស្រុក-ខ័ណ្ឌ ឬខេត្ត-ក្រុង ពណ៌ស ។ ផ្លាកសញ្ញាប្រភេទនេះសំរាប់ ប្រាប់អ្នកបើកបរអោយបានដឹង ពីទីកន្លែងដែលគេបានមកដល់ ឬ ចាកចេញ ក្នុងករណីដែលឃើញមាន ឆ្នូតក្រហមកាត់ ពីកំពូលក្រោមខាងឆ្វេងទៅកំពូលលើខាងស្តាំ ។

# ផ្នែកទី III ( ii ) : ផ្លាកសញ្ញាប្រាប់ ទីប្រជុំជន និង ព្រំប្រទល់តំបន់
## ( Buildup Area and Boundary Signs )




**ទីប្រជុំជន**

BUILD UP AREA

**លេខកូដ : PW03-G2-01**

**ខ្លឹមសារ** : សញ្ញានេះ ប្រើសំរាប់ប្រាប់ អោយអ្នកបើកបរ ដឹង អំពីការចូលមកដល់ ទីប្រជុំជន ។

---




**ចប់ ទីប្រជុំជន**

END BUILD UP AREA

**លេខកូដ : PW03-G2-02**

**ខ្លឹមសារ** : សញ្ញានេះ ប្រើសំរាប់ប្រាប់ អោយអ្នកបើកបរ ដឹង អំពីការ ចប់ ទីប្រជុំជន ។







**ព្រំប្រទល់ ខេត្ត ស្រុក ឬ ឃុំ**

PROVINCIAL, DISTRICT OR COMMUNE BOUNDARY

**លេខកូដ : PW03-G2-03**

**ខ្លឹមសារ** : សញ្ញានេះ ប្រើសំរាប់ប្រាប់ អោយអ្នកបើកបរ ដឹង អំពីការ ចូលមកដល់ ព្រំប្រទល់ ខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ ឬ ឃុំ-សង្កាត់។

---







**ចប់ ព្រំប្រទល់ ខេត្ត ស្រុក ឬ ឃុំ**

END PROVINCIAL, DISTRICT OR COMMUNE BOUNDARY

**លេខកូដ : PW03-G2-04**

**ខ្លឹមសារ** : សញ្ញានេះ ប្រើសំរាប់ប្រាប់ អោយអ្នកបើកបរ ដឹង អំពីការ ចប់ ព្រំប្រទល់ ខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ ឬ ឃុំ-សង្កាត់ ។

# ផ្នែកទី III ( iii )

# ផ្លាកសញ្ញាប្រាប់ឈ្មោះផ្លូវ

## Street name signs

ផ្លាកសញ្ញាប្រាប់ឈ្មោះផ្លូវមានរាងជាចតុកោណកែង ដែលមានជ្រុងដេកវែងជាងជ្រុងឈរ មានអក្សរពណ៌ស និង ផ្ទៃពណ៌ខៀវចាស់ ។

ផ្លាកសញ្ញាប្រភេទនេះដាក់សំរាប់ ប្រាប់ឈ្មោះផ្លូវផ្សេងៗ ដល់អ្នកបើកបរ ឬ អ្នកធ្វើដំណើរអោយបានដឹង ដើម្បីងាយស្រួលក្នុងការស្វែងរកទីតាំងណាមួយ ។

## ផ្នែកទី III ( iii ) : ផ្លាកសញ្ញាប្រាប់ឈ្មោះផ្លូវ
## ( Street Name Signs )




**មហាវិថី ព្រះនរោត្តម**

PREAH NORODOM BOULEVARD

**លេខកូដ : PW03-G3-01**

**ខ្លឹមសារ** : សញ្ញានេះ ប្រើសំរាប់ប្រាប់ ឈ្មោះមហាវិថីនានា អោយអ្នកប្រើប្រាស់ផ្លូវបានដឹង ។

---




**វិថី ព្រះត្រសក់ផ្អែម**

PREAH TRASAK PAEM STREET

**លេខកូដ : PW03-G3-02**

**ខ្លឹមសារ** : សញ្ញានេះ ប្រើសំរាប់ប្រាប់ ឈ្មោះវិថីនានា អោយអ្នកប្រើប្រាស់ផ្លូវបានដឹង ។

---




**រុក្ខវិថី ក្រមួនសរ**

KRAMUON SAR AVENUE

**លេខកូដ : PW03-G3-03**

**ខ្លឹមសារ** : សញ្ញានេះ ប្រើសំរាប់ប្រាប់ ឈ្មោះរុក្ខវិថីនានា អោយអ្នកប្រើប្រាស់ផ្លូវបានដឹង ។

---




**ផ្លូវលេខ ១១៣**

STREET No. 113

**លេខកូដ : PW03-G3-04**

**ខ្លឹមសារ** : សញ្ញានេះ ប្រើសំរាប់ប្រាប់ លេខផ្លូវនានា អោយអ្នកប្រើប្រាស់ផ្លូវបានដឹង ។

# ផ្នែកទី III ( iv )

# ផ្លាកសញ្ញាផ្តល់ដំណឹង

## Informative Signs

ផ្លាកសញ្ញាផ្តល់ដំណឹងមានរាងជាការេ ដែលមានជ្រុងពីរជាខ្សែឈរ និងជ្រុងពីរទៀតជាខ្សែដេក មានជាយ ពណ៌ស ពទ្ធ័ជុំវិញផ្ទៃពណ៌ខៀវ ឬ ស រូប ឬ សញ្ញាសំគាល់ ខាងក្នុងពណ៌ស (លើកលែង **ផ្លាកសញ្ញាសង្គ្រោះបន្ទាន់** ដែលមានសញ្ញាសំគាល់ខាងក្នុងពណ៌ក្រហម ផ្ទៃពណ៌ស និងសញ្ញា **ប្រយត្ន័ភ្លើងឆេះព្រៃ** ដែលមានស៊ុំពណ៌ក្រហម ផ្ទៃក្នុងពណ៌ស រូបសញ្ញាពណ៌ខៀវ-ក្រហម-លឿង ) ។

ផ្លាកសញ្ញាប្រភេទនេះ ជាទូទៅប្រើសំរាប់ប្រាប់ពត៌មាន ឬ ទីកន្លែងផ្សេងៗដល់អ្នកបើកបរ ឬ អ្នកធ្វើដំណើរបានដឹង ។




**កន្លែងចតយានជំនិះ**

PARKING AREA

**លេខកូដ : PW03-G4-01**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់ផ្តល់ដំណឹង ដល់អ្នកបើកបរអំពីទីកន្លែងអនុញ្ញាតអោយចត យានជំនិះ ។ បើចង់កំណត់ចំណតសំរាប់យានជំនិះប្រភេទណាមួយ ត្រូវដាក់សញ្ញាបន្ថែម ពីក្រោម សំរាប់យានប្រភេទនោះ ។

---




**កន្លែងចតយានជំនិះ បង់ប្រាក់**

PAY PARKING AREA

**លេខកូដ : PW03-G4-02**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់ផ្តល់ដំណឹង ដល់អ្នកបើកបរអំពីទីកន្លែងអនុញ្ញាតអោយចត យានជំនិះ តែត្រូវបង់ប្រាក់។ បើចង់កំណត់ចំណត សំរាប់យានជំនិះប្រភេទណា មួយ ត្រូវដាក់សញ្ញាបន្ថែមពីក្រោមសំរាប់យានប្រភេទនោះ ។

---



**កន្លែងថ្មើរជើងឆ្លងកាត់**

PEDESTRIAN CROSSING AREA

**លេខកូដ : PW03-G4-03**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់ផ្តល់ដំណឹង ដល់អ្នកប្រើប្រាស់ផ្លូវអំពី ទីកន្លែងសំរាប់ ថ្មើរជើងដែលត្រូវឆ្លងកាត់ ។

---



**កន្លែងទួល**

HUMP AREA

**លេខកូដ : PW03-G4-04**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់ផ្តល់ដំណឹង ដល់អ្នកបើកបរ អំពីកន្លែងមានទួល កាត់ទទឹងផ្លូវ ។



**កំពង់ចំលង ( សាឡាង )**

FERRY

**លេខកូដ : PW03-G4-05**

**ខ្លឹមសារ** : សញ្ញានេះ ប្រើសំរាប់ផ្តល់ដំណឹង ដល់អ្នកប្រើប្រាស់ផ្លូវ អំពី កន្លែងមានកំពង់ចំលង ដោយសាឡាង ។

---



**កន្លែងសង្គ្រោះបន្ទាន់**

FIRST AID

**លេខកូដ : PW03-G4-06**

**ខ្លឹមសារ** : សញ្ញានេះ ប្រើសំរាប់ផ្តល់ដំណឹង ដល់អ្នកប្រើប្រាស់ផ្លូវ អំពី កន្លែងសង្គ្រោះបន្ទាន់ ។

---



**មន្ទីរពេទ្យ**

HOSPITAL

**លេខកូដ : PW03-G4-07**

**ខ្លឹមសារ** : សញ្ញានេះ ប្រើសំរាប់ផ្តល់ដំណឹង ដល់អ្នកប្រើប្រាស់ផ្លូវ អំពី កន្លែងមានមន្ទីរពេទ្យ ។

---



**កន្លែងទូរសព្ទ**

TELEPHONE

**លេខកូដ : PW03-G4-08**

**ខ្លឹមសារ** : សញ្ញានេះ ប្រើសំរាប់ផ្តល់ដំណឹង ដល់អ្នកប្រើប្រាស់ផ្លូវ អំពី កន្លែងផ្តល់សេវាទូរសព្ទ សាធារណៈ ។



**កន្លែងផ្តល់ពត៌មាន**

OFFICIAL TOURIST INFORMATION

**លេខកូដ : PW03-G4-09**

**ខ្លឹមសារ** : សញ្ញានេះ ប្រើសំរាប់ផ្តល់ដំណឹង ដល់អ្នកប្រើប្រាស់ផ្លូវ ពិសេសអ្នកទេសចរណ៌ អំពីកន្លែងផ្តល់ពតឹមាន។

---



**ស្ថានីយ៍ចាក់ប្រេងឥន្ធនៈ**

FILLING STATION

**លេខកូដ : PW03-G4-10**

**ខ្លឹមសារ** : សញ្ញានេះ ប្រើសំរាប់ផ្តល់ដំណឹង ដល់អ្នកប្រើប្រាស់ផ្លូវ អំពីកន្លែងមាន ស្ថានីយ៍ប្រេងឥន្ធនៈ ។

---



**ស្ថានីយ៍ចាក់ប្រេងឥន្ធនៈ និង ជួសជុល**

FILLING STATION AND REPAIR

**លេខកូដ : PW03-G4-11**

**ខ្លឹមសារ** : សញ្ញានេះ ប្រើសំរាប់ផ្តល់ដំណឹង ដល់អ្នកប្រើប្រាស់ផ្លូវ អំពីកន្លែងមាន ស្ថានីយ៍ប្រេងឥន្ធនៈ និង ជួសជុលយានយន្ត ។

---



**យានដ្ឋាន ជួសជុល**

GARAGE STATION

**លេខកូដ : PW03-G4-12**

**ខ្លឹមសារ** : សញ្ញានេះ ប្រើសំរាប់ផ្តល់ដំណឹង ដល់អ្នកប្រើប្រាស់ផ្លូវ អំពីកន្លែងមាន យានដ្ឋានជួសជុលរថយន្ត។



**ភោជនីយដ្ឋាន**

RESTAURANT

**លេខកូដ : PW03-G4-13**

**ខ្លឹមសារ** : សញ្ញានេះ ប្រើសំរាប់ផ្តល់ដំណឹង ដល់អ្នកប្រើប្រាស់ផ្លូវ អំពីកន្លែងមាន ភោជនីយ៍ដ្ឋាន ។

---



**ភេសជ្ជៈដ្ឋាន**

CAFFETERIA

**លេខកូដ : PW03-G4-14**

**ខ្លឹមសារ** : សញ្ញានេះ ប្រើសំរាប់ផ្តល់ដំណឹង ដល់អ្នកប្រើប្រាស់ផ្លូវ អំពីកន្លែងមាន ភេសជៈដ្ឋាន ។

---



**សណ្ឋាគារ ឬ ផ្ទះសំណាក់**

HOTEL or GUEST HOUSE

**លេខកូដ : PW03-G4-15**

**ខ្លឹមសារ** : សញ្ញានេះ ប្រើសំរាប់ផ្តល់ដំណឹង ដល់អ្នកប្រើប្រាស់ផ្លូវ អំពីកន្លែងមាន សណ្ឋាគារ ឬ ផ្ទះសំណាក់។

---



**កន្លែងសំរាកកំសាន្ត**

REST AREA

**លេខកូដ : PW03-G4-16**

**ខ្លឹមសារ** : សញ្ញានេះ ប្រើសំរាប់ផ្តល់ដំណឹង ដល់អ្នកប្រើប្រាស់ផ្លូវ អំពីកន្លែងសំរាកកំសាន្ត ។



**ព្រលានយន្តហោះ**

AIRPORT

**លេខកូដ : PW03-G4-17**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់ផ្តល់ដំណឹង ដល់អ្នកប្រើប្រាស់ផ្លូវ អំពីទីកន្លែងមាន ព្រលានយន្តហោះ ។



**កន្លែងរំកិលទូកចុះទឹក**

BOAD RAMP

**លេខកូដ : PW03-G4-18**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់ផ្តល់ដំណឹង ដល់អ្នកប្រើប្រាស់ផ្លូវ អំពីទីកន្លែងរំកិលទូកចុះទឹក ។



**កន្លែងបោះតង់កំសាន្ត**

CAMPING AREA

**លេខកូដ : PW03-G4-19**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់ផ្តល់ដំណឹង ដល់អ្នកប្រើប្រាស់ផ្លូវ អំពីទីកន្លែងបោះតង់កំសាន្ត ។



**កន្លែងចតរ៉ឺម៉ករថយន្តកំសាន្ត**

MARAVEN PARK OR SITE

**លេខកូដ : PW03-G4-20**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់ផ្តល់ដំណឹង ដល់អ្នកប្រើប្រាស់ផ្លូវ អំពីទីកន្លែងចតរ៉ឺម៉ករថយន្តកំសាន្ត ។



**កន្លែងបោះតង់ និង ចតរ៉ឺម៉ករថយន្តកំសាន្ត**

CARAVAN PARK AND CAMPING AREA

**លេខកូដ : PW03-G4-21**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់ផ្តល់ដំណឹង ដល់អ្នកប្រើប្រាស់ផ្លូវ អំពីទីកន្លែងបោះតង់ និង ចតរ៉ឺម៉ករថយន្តកំសាន្ត។

---




**ចំណតរថយន្តតាក់ស៊ី**

TAXI STATION

**លេខកូដ : PW03-G4-22**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់ផ្តល់ដំណឹង ដល់អ្នកប្រើប្រាស់ផ្លូវ អំពីទីកន្លែង មានចំណតរថយន្តតាក់ស៊ី។

---



**បន្ទប់អនាម័យ**

TOILETES

**លេខកូដ : PW03-G4-23**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់ផ្តល់ដំណឹង ដល់អ្នកប្រើប្រាស់ផ្លូវ អំពីទីកន្លែង មានបន្ទប់អនាម័យ ។

---



**ទឹកបរិភោគ**

DRINKING WATER

**លេខកូដ : PW03-G4-24**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់ផ្តល់ដំណឹង ដល់អ្នកប្រើប្រាស់ផ្លូវ អំពីទីកន្លែង មានទឹកបរិភោគ ។



**កន្លែងមានធុងសំរាម**

LITTER BIN

**លេខកូដ : PW03-G4-25**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់ផ្តល់ដំណឹង ដល់អ្នកប្រើប្រាស់ផ្លូវ អំពីទីកន្លែង មានធុងដាក់សំរាម ។

---



**អនុញ្ញាតអោយជិះទោចក្រយានទន្ទឹមគ្នា**

ABREAST TRAVELING PERMITED FOR BYCICLE

**លេខកូដ : PW03-G4-26**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់ផ្តល់ដំណឹង ដល់អ្នកប្រើប្រាស់ផ្លូវ អំពីទីកន្លែង អនុញ្ញាតិអោយ ជិះទោចក្រយាន ទន្ទឹមគ្នាបាន ។

---



**ផ្លូវទាល់ខាងមុខ**

NO THROUGH ROAD

**លេខកូដ : PW03-G4-27**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់ផ្តល់ដំណឹង ដល់អ្នកប្រើប្រាស់ផ្លូវ អោយដឹងថា ផ្លូវខាងមុខត្រង់ ជាផ្លូវទាល់ ។

---



**ផ្លូវបត់ទៅស្តាំជាផ្លូវទាល់**

NO THROUGH ROAD  ON RIGHT ROAD

**លេខកូដ : PW03-G4-28**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់ផ្តល់ដំណឹង ដល់អ្នកប្រើប្រាស់ផ្លូវ អោយដឹងថា ផ្លូវបត់ស្តាំ ជាផ្លូវទាល់ ។



**ផ្លូវបត់ទៅឆ្វេងជាផ្លូវទាល់**

NO THROUGH ROAD  ON LEFT ROAD

**លេខកូដ : PW03-G4-29**

**ខ្លឹមសារ** : សញ្ញានេះ  ប្រើសំរាប់ផ្តល់ដំណឹង  ដល់អ្នកប្រើប្រាស់ផ្លូវ
អោយដឹងថា ផ្លូវបត់ឆ្វេង ជាផ្លូវទាល់ ។

---



**យន្តបថ**

MOTOR WAY

**លេខកូដ : PW03-G4-30**

**ខ្លឹមសារ** : សញ្ញានេះ  ប្រើសំរាប់ផ្តល់ដំណឹង  ដល់អ្នកបើកបរ  អំពី
កន្លែងចាប់ផ្តើម ចូលផ្លូវយន្តបថ ។

---



**ចប់  យន្តបថ**

END OF MOTOR WAY

**លេខកូដ : PW03-G4-31**

**ខ្លឹមសារ** : សញ្ញានេះ  ប្រើសំរាប់ផ្តល់ដំណឹង  ដល់អ្នកបើកបរ  អំពី
កន្លែង បញ្ចប់ ផ្លូវយន្តបថ ។

---



**ចំណែកផ្លូវធ្វើចរាចរ**

( ចំណែកខាងឆ្វេងសំរាប់រថយន្ត ចំណែកកណ្តាលសំរាប់
ទោចក្រយានយន្ត ចំណែកខាងស្តាំសំរាប់ថ្មើរជើង )

COMPULSORY LANES

**លេខកូដ : PW03-G4-32**

**ខ្លឹមសារ** : សញ្ញានេះ  ប្រើសំរាប់ផ្តល់ដំណឹង  ដល់អ្នកប្រើប្រាស់ផ្លូវ
អំពី  ចំណែកផ្លូវធ្វើចរាចរ តាមប្រភេទ  អ្នកប្រើប្រាស់ផ្លូវ
ដូចមានបង្ហាញ ក្នុងផ្ទាកសញ្ញា ។



**គន្លងផ្លូវ បី រួមជា ពីរ (ទៅខាងស្តាំ )**

3 LANES REDUCE IN 2 LANES

**លេខកូដ : PW03-G4-33**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់ផ្តល់ដំណឹង ដល់អ្នកបើកបរ អំពី គន្លងផ្លូវខាងឆ្វេង រួមចូលគន្លងផ្លូវកណ្តាល ជាគន្លងតែមួយ ។

---



**គន្លងផ្លូវ បី រួមជា ពីរ (ទៅខាងឆ្វេង )**

3 LANES REDUCE IN 2 LANES

**លេខកូដ : PW03-G4-34**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់ផ្តល់ដំណឹង ដល់អ្នកបើកបរ អំពី គន្លងផ្លូវខាងស្តាំ រួមចូលគន្លងផ្លូវកណ្តាល ជាគន្លងតែមួយ ។

---



**ផ្លូវវាងបត់ឆ្វេង**

DETOUR FOR TURNING LEFT

**លេខកូដ : PW03-G4-35**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់ផ្តល់ដំណឹង ដល់អ្នកបើកបរ អំពី ផ្លូវដែលត្រូវវាង ដើម្បីបត់ឆ្វេង ព្រោះមានសញ្ញា **ហាមបត់ឆ្វេង** នៅផ្លូវប្រសព្វខាងមុខ ។

---




**ផ្លូវវាងចំពោះយានដែលមានកំពស់សរុបលើស 3.3ម**

DETOUR FOR VEHICLE HAVING OVERALL HEIGHT EXCEEDING THE SPECIFIED HEIGHT

**លេខកូដ : PW03-G4-36**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់ផ្តល់ដំណឹង ដល់អ្នកបើកបរយានដែលមានកំពស់សរុបលើស ការកំណត់ក្នុងផ្លាកសញ្ញា អោយបើកបរវាងទៅតាមទិសនៃផ្លាកសញ្ញា ព្រោះមានសញ្ញា **កំណត់កំពស់** នៅខាងមុខ ។



**គន្លងផ្លូវត្រូវធ្វើចរាចរ**
(ចំណែកខាងស្តាំសំរាប់អ្នកបត់ស្តាំ ចំណែកកណ្តាលសំរាប់អ្នកទៅមុខត្រង់ និង ចំណែកខាងឆ្វេងសំរាប់អ្នកទៅមុខត្រង់ ឬ បត់ឆ្វេង)
ARROW DIRECTION EXCLUSIVE LANE

**លេខកូដ : PW03-G4-37**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់ផ្តល់ដំណឹង ដល់អ្នកបើកបរ អំពីទិសដៅបើកបរ ដែលត្រូវប្រកាន់យក ទៅតាមសញ្ញាព្រួញ នៅពេលខិតជិតដល់ ផ្លូវប្រសព្វខាងមុខ ។

---



**គន្លងផ្លូវត្រូវធ្វើចរាចរ**
(ចំណែកផ្លូវនេះសំរាប់អ្នកទៅមុខត្រង់ ឬ បត់ឆ្វេង)
ARROW DIRECTION EXCLUSIVE LANE

**លេខកូដ : PW03-G4-38**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់ផ្តល់ដំណឹង ដល់អ្នកបើកបរ អំពីទិសដៅបើកបរ ដែលត្រូវប្រកាន់យក ទៅតាមសញ្ញាព្រួញ នៅពេលខិតជិតដល់ ផ្លូវប្រសព្វខាងមុខ ។

---



**ផ្លូវឯកទិស**
ONE WAY TRAFFIC

**លេខកូដ : PW03-G4-39**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់ផ្តល់ដំណឹង ដល់អ្នកបើកបរ អំពីផ្លូវឯកទិស ដែលអនុញ្ញាតអោយធ្វើ ចរាចរបានតែមួយទិស តាមសញ្ញាព្រួញ ។

---




**ប្រយត្ន័ភ្លើងឆេះព្រៃ**
FOREST FIRE WARNING SIGN

**លេខកូដ : PW03-G4-40**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់ផ្តល់ដំណឹង ដល់អ្នកប្រើប្រាស់ផ្លូវអោយដឹងថា មានព្រៃដែលស្ងួតងាយឆេះ សូមធ្វើការប្រុងប្រយត្ន័ ភ្លើង ។

# ផ្នែកទី IV ( i )

# ផ្លាកសញ្ញាដាក់បន្ថែមពីក្រោម

## Supplementary signs

ផ្លាកសញ្ញាសំរាប់បន្ថែមពីក្រោមមានរាងជា ចតុកោណកែង ដែលមានស៊ុំពណ៌ខ្មៅ ផ្ទៃខាងក្រោយពណ៌ស រូប ឬ សញ្ញាសំគាល់ខាងក្នុង ពណ៌ខ្មៅ ( លាយពណ៌ក្រហម-លឿង តែចំពោះ ផ្លាកសញ្ញា សំគាល់យានផ្ទុកផលិតផលងាយឆេះ ដែលមានលេខកូដ **PW03-S1-25** ) ។

ផ្លាកសញ្ញាប្រភេទនេះ ប្រើជាជំនួយសំរាប់ដាក់បន្ថែមពីក្រោមផ្លាកសញ្ញា ដូចមានខាងដើម ដើម្បីបញ្ជាក់អត្ថន័យ អោយបានច្បាស់លាស់ថែមទៀត ដូចជា ប្រភេទយានជំនិះ ចម្ងាយ ទិសដៅ ពេលវេលា រូបសញ្ញា ឬ ពាក្យដែលចាំបាច់ ។



**ទោចក្រយាន**

BICYCLE

**លេខកូដ : PW03-S1-01**

**ខ្លឹមសារ** : សញ្ញានេះ ប្រើសំរាប់សំគាល់ ទោចក្រយាន ។

---



**ទោចក្រយានយន្ត**

MOTORCYCLE

**លេខកូដ : PW03-S1-02**

**ខ្លឹមសារ** : សញ្ញានេះ ប្រើសំរាប់សំគាល់ ទោចក្រយានយន្ត ។

---



**ទោចក្រយានមានរ៉ឺម៉កសណ្តោង**

MOTORCYCLE DRAWN VEHICLES

**លេខកូដ : PW03-S1-03**

**ខ្លឹមសារ** : សញ្ញានេះ ប្រើសំរាប់សំគាល់ ប្រភេទទោចក្រយាន មាន រ៉ឺម៉កសណ្តោង ។

---



**រថយន្តធុនតូច**

MOTOR VEHICLES

**លេខកូដ : PW03-S1-04**

**ខ្លឹមសារ** : សញ្ញានេះ ប្រើសំរាប់សំគាល់ ប្រភេទរថយន្តធុនតូច ដែលអាចផ្ទុកមនុស្ស មិនលើស ៩ នាក់ គិតទាំងអ្នកបើកបរ ឬ ផ្ទុកទំនិញ មិនលើស ៣.៥០តោន ។

---



**រថយន្តដឹកអ្នកដំណើរធុនធំ**

LARGE SIZED BUS

**លេខកូដ : PW03-S1-05**

**ខ្លឹមសារ** : សញ្ញានេះ ប្រើសំរាប់សំគាល់ ប្រភេទរថយន្តដឹកអ្នកដំណើរធុនធំ ដែលអាចផ្ទុកអ្នកដំណើរយ៉ាងតិច ២០នាក់ គិតទាំងអ្នកបើកបរ ។



**រថយន្តដឹកទំនិញធុនធំ**
LARGE SIZED TRUCK

**លេខកូដ : PW03-S1-06**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់សំគាល់ រថយន្តដឹកទំនិញ ធុនធំ ដែលជា ប្រភេទរថយន្តអាចមានទំងន់សរុប លើស ៣.៥០ តោន ។

---



**យានយន្តកសិកម្ម**
AGRICULTURAL MOTOR VEHICLES

**លេខកូដ : PW03-S1-07**

**ខ្លឹមសារ :** សញ្ញានេះប្រើសំរាប់សំគាល់ ប្រភេទយានយន្តកសិកម្ម ។

---



**រទេះអូសទាញដោយសត្វ**
ANIMAL DRAWN VEHICLES

**លេខកូដ : PW03-S1-08**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់សំគាល់ ប្រភេទរទេះអូសទាញ ដោយសត្វ ។

---




**យានមានទំងន់ផ្ទុកលើភ្លៅនិមួយៗ លើស ២ តោន**
VEHICLES HAVING OVER ALL WEIGHT ON
AXLE EXCEEDING THE SPECIFIED WEIGHT

**លេខកូដ : PW03-S1-09**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់សំគាល់ ប្រភេទយានដែលមាន ទំងន់ផ្ទុកលើភ្លៅណាមួយលើសទំនង់កំណត់ក្នុងសញ្ញា ។

---




**រថយន្តដឹកទំនិញធុនធំ ដែលមានបណ្ដោយលើស ១០ម**
LARGE SIZE TRUCK HAVING OVER ALL
LENGHT EXCEEDING THE SPECIFIED LENGHT

**លេខកូដ : PW03-S1-10**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់សំគាល់ចំពោះ ប្រភេទរថយន្តដឹក ទំនិញធុនធំ ដែលមានបណ្ដោយសរុប គិតទាំងបន្ទុក លើស ប្រវែងកំណត់ក្នុងសញ្ញា ។




**យានដែលមានទទឹងលើស ២ម**

VEHICLES HAVING OVER ALL WIDTH
EXCEEDING THE SPECIFIED WIDTH

**លេខកូដ : PW03-S1-11**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់ សំគាល់ចំពោះ ប្រភេទយានដែលមានទទឹងសរុប លើស ប្រវែងកំណត់ក្នុងសញ្ញា ។

---




**យានដែលមានកំពស់លើស ៣.៥០ម**

VEHICLES HAVING OVER ALL HEIGHT
EXCEEDING THE SPECIFIED HEIGHT

**លេខកូដ : PW03-S1-12**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់សំគាល់ ប្រភេទយានដែលមាន កំពស់សរុប គិតទាំងបន្ទុក លើសកំពស់កំណត់ ក្នុងសញ្ញា ។

---



**ទៅខាងស្តាំដៃ**

TO THE RIGHT HAND SIDE

**លេខកូដ : PW03-S1-13**

**ខ្លឹមសារ :** សញ្ញានេះ ច្រើនប្រើពីក្រោមសញ្ញា **ហាមចត** ឬ **ឈប់** ដើម្បី សំគាល់ទីតាំងហាមចត ពីផ្លាកសញ្ញាទៅខាងស្តាំដៃ ។

---



**ទៅខាងស្តាំ និង ខាងឆ្វេងដៃ**

TO THE RIGHT AND LEFT HAND SIDE

**លេខកូដ : PW03-S1-14**

**ខ្លឹមសារ :** សញ្ញានេះ ច្រើនប្រើពីក្រោមសញ្ញា **ហាមចត** ឬ **ឈប់** ដើម្បីសំគាល់ ទីតាំងហាមចត ពីផ្លាកសញ្ញា ទៅខាងស្តាំ និង ទៅខាងឆ្វេងដៃ ។

---



**ទៅខាងឆ្វេងដៃ**

TO THE LEFT HAND SIDE

**លេខកូដ : PW03-S1-15**

**ខ្លឹមសារ :** សញ្ញានេះ ច្រើនប្រើពីក្រោមសញ្ញា **ហាមចត** ឬ **ឈប់** ដើម្បី សំគាល់ទីតាំងហាមចត ពីផ្លាកសញ្ញា ទៅខាងឆ្វេងដៃ ។



**ទៅខាងមុខ**

FORWARD

**លេខកូដ : PW03-S1-16**

**ខ្លឹមសារ :** សញ្ញានេះ ច្រើនប្រើពីក្រោមសញ្ញា **ហាមចត** ឬ **ឈប់** ដើម្បីសំគាល់ទីតាំងហាមចតចាប់ពីផ្លាកសញ្ញាទៅមុខ ។

---



**ទៅខាងមុខ និង មកខាងក្រោយ**

FORWARD AND BACKWARD

**លេខកូដ : PW03-S1-17**

**ខ្លឹមសារ :** សញ្ញានេះ ច្រើនប្រើពីក្រោមសញ្ញា **ហាមចត** ឬ **ឈប់** ដើម្បី សំគាល់ទីតាំងហាមចត ចាប់ពីផ្លាកសញ្ញាទៅមុខ និង មកខាងក្រោយ ។

---



**មកខាងក្រោយ**

BACKWARD

**លេខកូដ : PW03-S1-18**

**ខ្លឹមសារ :** សញ្ញានេះ ច្រើនប្រើពីក្រោមសញ្ញា **ហាមចត** ឬ **ឈប់** ដើម្បី សំគាល់ទីតាំងហាមចត ចាប់ពីផ្លាកសញ្ញា មកខាង ក្រោយ ។

---




**ប្រយ័ត្ន ! រថភ្លើងឆ្លងកាត់**

BEWARE OF TRAIN
(When approaching the railway line)

**លេខកូដ : PW03-S1-19**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់ បញ្ជាក់បន្ថែម ពីប្រភេទគ្រោះថ្នាក់ ពិសេស គឺ មានរថភ្លើងឆ្លងកាត់។




**ច្រកចេញចូលរោងចក្រ**

FACTORY’S GATE

**លេខកូដ : PW03-S1-20**

**ខ្លឹមសារ** : សញ្ញានេះ ប្រើសំរាប់បញ្ជាក់បន្ថែម ពីប្រភេទគ្រោះថ្នាក់ពិសេស គឺ មានច្រកចេញចូលរោងចក្រ។ ពាក្យនៅក្នុងផ្លាកសញ្ញា អាចផ្លាស់ប្តូរទៅតាម ប្រភេទតំបន់គ្រោះថ្នាក់ ដូចជា ” **ច្រកចេញចូលកំពង់ផែ** ” ” **ច្រកចេញចូលសួនកំសាន្ត** ”។ល។ តែទំហំអក្សរត្រូវតែអាចអានបានច្បាស់ ក្នុងចំងាយយ៉ាងតិច ២០ម ។

---



**បង្ហាញទិសដៅ ផ្លូវធំមានសិទ្ធិ**

DIRECTION OF PRIORITY ROAD

**លេខកូដ : PW03-S1-21**

**ខ្លឹមសារ** : គំនូសក្រាស់ សំរាប់សំគាល់ផ្លូវធំមានសិទ្ធិ ។ គំនូសស្តើង សំរាប់សំគាល់ផ្លូវតូចបាត់សិទ្ធិ ។ អ្នកបើកបរ កំពុងស្ថិតនៅលើផ្លូវធំមានសិទ្ធិ ។

---



**បង្ហាញទិសដៅ ផ្លូវធំមានសិទ្ធិ**

DIRECTION OF PRIORITY ROAD

**លេខកូដ : PW03-S1-22**

**ខ្លឹមសារ** : គំនូសស្តើង សំរាប់សំគាល់ផ្លូវតូចបាត់សិទ្ធិ ។ គំនូសក្រាស់ សំរាប់សំគាល់ផ្លូវធំមានសិទ្ធិ ។ អ្នកបើកបរ កំពុងស្ថិតលើ ផ្លូវតូចបាត់សិទ្ធិ ។

---




**បង្ហាញចំងាយ**

DISTANCE IDENTIFICATION

**លេខកូដ : PW03-S1-23**

**ខ្លឹមសារ** : សញ្ញានេះ ប្រើសំរាប់ បញ្ជាក់បន្ថែម នូវចំងាយ ។ លេខនៅក្នុងផ្លាកសញ្ញា អាចផ្លាស់ប្តូរទៅតាម ចំងាយជាក់ស្តែងតែទំហំអក្សរ ត្រូវតែអាចអានបានច្បាស់ ក្នុង ចំងាយយ៉ាងតិច ២០ម ។




**បង្ហាញពេលវេលា**

TIME IDENTIFICATION

**លេខកូដ : PW03-S1-24**

**ខ្លឹមសារ** : សញ្ញានេះ ប្រើសំរាប់ បញ្ជាក់បន្ថែម នូវពេលវេលា ។ លេខនៅក្នុងផ្លាកសញ្ញា អាចផ្លាស់ប្តូរទៅតាម ពេលវេលាជាក់ស្តែង តែទំហំអក្សរត្រូវតែអាចអានបានច្បាស់ ក្នុងចំងាយយ៉ាងតិច ២០ម ។

---



**យានផ្ទុកផលិតផលងាយឆេះ**

VEHICLES LOADING INFLAMMABLE GOODS

**លេខកូដ : PW03-S1-25**

**ខ្លឹមសារ** : សញ្ញានេះ ប្រើសំរាប់សំគាល់ យានគ្រប់ប្រភេទដែលមាន ផ្ទុកផលិតផលងាយឆេះ ។

# ផ្នែកទី V ( i )

# បង្គោលសញ្ញា

## Sign Posts

បង្គោលសញ្ញា មានច្រើនប្រភេទ ដែលមានទ្រង់ទ្រាយផ្សេងៗពីគ្នា ដូចជាខ្លះមាន រាងមូល ខ្លះរាងជ្រុង ខ្លះរាងចតុកោណព្នាយ ខ្លះរាងជាបន្ទះ ។ល។

បង្គោលសញ្ញា ប្រើក្នុងគោលបំណងផ្សេងៗគ្នា ដូចជាបង្គោលសំរាប់តំរង់ផ្លូវ សំរាប់ជួយសំរួលអ្នកបើកបរ ពិសេសនៅពេលយប់ អោយងាយដឹងពីការបត់បែនរបស់ផ្លូវ ។ បង្គោលដាក់នៅតាមផ្លូវកោងគ្រោះថ្នាក់ សំរាប់អោយអ្នកបើកបរ ងាយដឹង និងប្រុងប្រយ័ត្ន នៅកន្លែងផ្លូវកោងគ្រោះថ្នាក់ដោយមានចំណោតឡើង ចុះ ឬ មានជ្រោះ ។ បង្គោលដាក់នៅលើ កន្លែងមានឧបសគ្គ ដូចជា ក្បាលស្ពាន ខឿន ឬ សូនច្បារ សំរាប់អោយអ្នកបើកបរ ប្រុងប្រយ័ត្ន ។ បង្គោលគីឡូមែត្រ សំរាប់បង្ហាញចំងាយ ទៅតំបន់ផ្សេងៗ ។

# ផ្នែកទី V ( i ) : បង្គោលសញ្ញា ( Sign Posts )



### បង្គោលសញ្ញាផ្លូវកោង ឬ តំរង់ផ្លូវ
DELINEATOR POST

**លេខកូដ : PW03-P1-01**

**ខ្លឹមសារ :** បង្គោលសញ្ញានេះ ប្រើសំរាប់បង្ហាញ អ្នកបើកបរ អោយដឹង ពីផ្លូវកោងលើផ្ទៃរាបស្មើ ឬប្រើសំរាប់តំរង់ផ្លូវបើកបរមិនអោយងាកចេញពីទ្រូងផ្លូវ ពិសេសនៅពេលយប់ ព្រោះ មានបំពាក់បន្ទះចំណាំងផ្លាត នៅចន្លោះ ផ្ទៃខ្មៅ។

---



### បង្គោលសញ្ញាផ្លូវកោង (កោងគ្រោះថ្នាក់)
GUIDE POST ( AT DENGEROUS CURVE )

**លេខកូដ : PW03-P1-02**

**ខ្លឹមសារ :** បង្គោលសញ្ញានេះ ប្រើសំរាប់បង្ហាញ អ្នកបើកបរ អោយដឹង ពីផ្លូវកោងគ្រោះថ្នាក់ ដោយចុះឡើងចំណោត ឬ មាត់ជ្រោះ ។

---



### សញ្ញាឈើរបារផ្លូវកោងទៅស្តាំ
LATERAL SHIFT MARKER (TO RIGHT)

**លេខកូដ : PW03-P1-03**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់បង្ហាញ អ្នកបើកបរអោយប្រុងប្រយ័ត្ន ផ្លូវកោងទៅស្តាំ ។

---



### សញ្ញាឈើរបារផ្លូវកោងទៅឆ្វេង
LATERAL SHIFT MARKER (TO LEFT)

**លេខកូដ : PW03-P1-04**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់បង្ហាញ អ្នកបើកបរអោយប្រុងប្រយ័ត្ន ផ្លូវកោងទៅឆ្វេង ។



**សញ្ញាបង្ហាញឧបសគ្គ នៅខាងស្តាំ**

OBJECT MARKER (ON THE RIGHT)

**លេខកូដ : PW03-P1-05**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់បង្ហាញ អ្នកបើកបរ ប្រុងប្រយ័ត្ន មានឧបសគ្គនៅខាងស្តាំ ដូចជា បង្គោលក្បាលស្ពាន ឬ ខឿនលើទ្រូងផ្លូវ ។ល។

---



**សញ្ញាបង្ហាញឧបសគ្គ នៅលើទ្រូងផ្លូវ**

OBJECT MARKER (AT CENTER)

**លេខកូដ : PW03-P1-06**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់បង្ហាញ អ្នកបើកបរ ប្រុងប្រយ័ត្ន មានឧបសគ្គនៅលើទ្រូងផ្លូវឯកទិស ដូចជា ខឿន ឬ សួនច្បារ ។

---



**សញ្ញាបង្ហាញឧបសគ្គ នៅខាងឆ្វេង**

OBJECT MARKER (ON THE LEFT)

**លេខកូដ : PW03-P1-07**

**ខ្លឹមសារ :** សញ្ញានេះ ប្រើសំរាប់បង្ហាញ អ្នកបើកបរ ប្រុងប្រយ័ត្ន មានឧបសគ្គនៅខាងឆ្វេង ដូចជា បង្គោលក្បាលស្ពាន ឬ ខឿនលើទ្រូងផ្លូវ ។ល។

---



1 2 3

**បង្គោលសញ្ញាផ្លូវរថភ្លើងឆ្លងកាត់**

RAILWAY CROSSING POST

**លេខកូដ : PW03-P1-08**

**ខ្លឹមសារ :** បង្គោលសញ្ញានេះ ប្រើសំរាប់ ផ្តល់ដំណឹងអោយអ្នកបើកបរប្រុងប្រយត្ន័ មានផ្លូវរថភ្លើងឆ្លងកាត់ ១៥០ម៉ែត្រ ខាងមុខ (រូបទី 1 ), ១០០ម៉ែត្រ ខាងមុខ (រូបទី 2 ) និង ៥០ម៉ែត្រ ខាងមុខ (រូបទី 3 ) ។

## បង្គោលគីឡូម៉ែត្រ (សម្រាប់ចន្លោះ ១០ គ.ម)

KILOMETER POST (FOR 10Km INTERVAL)




**លេខកូដ ៖** **PW03-P1-09**

**ខ្លឹមសារ ៖** បង្គោលសញ្ញានេះ ប្រើសម្រាប់ផ្តល់ដំណឹងដល់អ្នកប្រើប្រាស់ផ្លូវអំពីចម្ងាយផ្លូវ ទៅតំបន់សំខាន់ៗខាងមុខ។ បង្គោលសញ្ញាប្រភេទនេះ មានក្នុងចន្លោះ ដប់គីឡូម៉ែត្រមួយដោយដាក់ជំនួស លើទីតាំងបង្គោលគីឡូម៉ែត្រធម្មតា (P1-10)។

នៅលើជើងតាង ឬ ទីតាំងក្បែរបង្គោលនេះ មានភ្ជាប់នូវ Bench Mark។

---

## បង្គោលគីឡូម៉ែត្រ (សម្រាប់ចន្លោះ ១ គ.ម)

KILOMETER POST (FOR 1Km INTERVAL)




**លេខកូដ ៖** **PW03-P1-10**

**ខ្លឹមសារ ៖** បង្គោលសញ្ញានេះ ត្រូវដាក់ខាងឆ្វេងដៃ តាមទិសដៅចេញពីរាជធានីភ្នំពេញ ក្នុងចន្លោះ១គីឡូម៉ែត្រមួយ សម្រាប់ផ្តល់ដំណឹងដល់អ្នកប្រើប្រាស់ផ្លូវអំពីចម្ងាយផ្លូវ ទៅតំបន់សំខាន់ៗខាងមុខ។

លេខបង្គោលដែលនៅលើផ្ទៃក្រហម បង្ហាញចម្ងាយផ្លូវ៖

- ចេញពីរាជធានីភ្នំពេញ ចំពោះផ្លូវជាតិដែលមានលេខ ១ខ្ទង់,
- ចេញពីចំណុចបំបែក ចំពោះផ្លូវជាតិដែលមានលេខ ២ខ្ទង់ និងផ្លូវខេត្តដែលមានលេខពី ៣ខ្ទង់។

ក្នុងចន្លោះ ដប់គីឡូម៉ែត្រម្តង បង្គោលសញ្ញានេះ ត្រូវដាក់ជំនួសដោយបង្គោលសញ្ញាលេខ P1-09។

## ខ - ភ្លើងសញ្ញាចរាចរណ៍

### TRAFFIC LIGHTS

ភ្លើងសញ្ញាចរាចរណ៍ ប្រើសម្រាប់ បញ្ជា និង សម្រួលចរាចរណ៍ ដោយបែងចែកពេលវេលាត្រឹមត្រូវ សម្រាប់ទិសដៅចរាចរណ៍នីមួយៗ ដើម្បីកាត់បន្ថយភាពកកស្ទះ ក្នុងការប្រជែងដណ្តើមគ្នាទៅមុន និងកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ទាំងអ្នកបើកបរ ទាំងថ្មើរជើង។ ភ្លើងសញ្ញាចរាចរណ៍ ភាគច្រើនប្រើនៅត្រង់ផ្លូវប្រសព្វ ឬ ត្រង់ផ្លូវមានគំនូសសញ្ញាសម្រាប់ថ្មើរជើងឆ្លងកាត់។

ភ្លើងសញ្ញាចរាចរណ៍ មាន **បី** ប្រភេទ ៖

លេខសម្គាល់ ៖ **PW03-L1-00**

**ប្រភេទ ទី១** : ភ្លើងសញ្ញាចរាចរណ៍ បីព័ណ៌ សម្រាប់បញ្ជា និងសម្រួលចរាចរណ៍ទូទៅដល់ អ្នកបើកបរយានជំនិះគ្រប់ប្រភេទលើផ្លូវសាធារណៈ។ ក្នុងប្រភេទទី១ នេះ មានភ្ជាប់ជាមួយនូវភ្លើងសញ្ញា ពីរព័ណ៌ សម្រាប់បញ្ជាចរាចរណ៍ថ្មើរជើងឆ្លងកាត់។

**ប្រភេទ ទី២** : ភ្លើងសញ្ញាចរាចរណ៍ ពីរព័ណ៌ សម្រាប់បញ្ជាអ្នកបើកបរយានជំនិះនៅត្រង់បញ្ជរបង់ប្រាក់ថ្លៃប្រើប្រាស់ផ្លូវ ឬ ច្រកចេញចូលដែលចាំបាច់។

**ប្រភេទ ទី៣** : ភ្លើងសញ្ញាចរាចរណ៍ មួយព័ណ៌ ភ្លឹបភ្លែតៗ សម្រាប់បញ្ជាអ្នកបើកបរយានជំនិះឱ្យប្រុងប្រយ័ត្ន បន្ថយល្បឿន ឬ ឈប់។

## ប្រភេទ ទី១ : ភ្លើងសញ្ញាចរាចរណ៍ បីព៌ណ៌ (Three Color Traffic Lights)


01a.


01b.


01c.

### ភ្លើងសញ្ញាចរាចរណ៍បីព៌ណ៌ ជារង្វង់

THREE COLORED CIRCULAR LIGHTS

**លេខកូដ** : PW03-L1-01

**ខ្លឹមសារ** : ភ្លើងសញ្ញានេះ ប្រើសម្រាប់បញ្ជា និងសម្រួលចរាចរណ៍ មួយ ឬ ច្រើនគន្លង រួមគ្នានៅត្រង់ផ្លូវប្រសព្វ ឬ ត្រង់ផ្លូវមានគំនូសសញ្ញាសម្រាប់ថ្មើរជើងឆ្លងកាត់។

<u>ពណ៌និមួយៗនៃភ្លើងសញ្ញា មានអត្ថន័យដូចខាងក្រោម:</u>

-<u>ពណ៌ក្រហម</u> ( រូប **01a.** ):

ត្រូវឈប់នៅមុខ គំនូសសញ្ញាឈប់ ។

-<u>ពណ៌លឿង</u> ( រូប **01b.** ):

ត្រូវប្រុងប្រយត្ន័ ត្រៀមឈប់ ប៉ុន្តែបើអ្នកបើកបរ ចូលកៀកផ្លូវប្រសព្វ ឬគំនូសសញ្ញាថ្មើរជើងឆ្លងកាត់ ដែលពុំអាចបញ្ឈប់យានរបស់ខ្លួនបាន ដោយសុវត្ថិភាព គេអាចបន្តដំណើរបាន ដោយប្រុងប្រយត្ន័ ។


01d.

-<u>ពណ៌បៃតង</u> ( រូប **01c.** ):

អនុញ្ញាតបន្តដំណើរបាន បើផ្លូវទំនេរ និង ជឿជាក់ថាអាច ឆ្លងផុតផ្លូវប្រសព្វ ដោយមិនបង្កភាពកកស្ទះ ។

ក្នុងករណី មានភ្ជាប់បន្ថែម សញ្ញាព្រួញ ពណ៌បៃតងចង្អុលទៅខាងស្តាំ ដូចក្នុង រូប **01d.** ( អាចជាភ្លើងអគ្គីសនី ឬ ជាផ្លាកគំនូរ ) នៅពេលមានភ្លើងក្រហម អាចអនុញ្ញាតបត់ស្តាំបានដោយប្រុងប្រយត្ន័ ប្រសិនបើផ្លូវទំនេរ ។

---

### ភ្លើងសញ្ញាចរាចរណ៍ សម្រាប់ថ្មើរជើងឆ្លងកាត់

(ប្រើជាមួយ ភ្លើងសញ្ញាចរាចរណ៍បីព៌ណ៌ ជារង្វង់)

PEDESTRIAN CROSSING LIGHTS
(UDED WITH THREE COLORED CIRCULAR LIGHTS)


02a.


02b.

**លេខកូដ** : PW03-L1-02

**ខ្លឹមសារ** : ភ្លើងសញ្ញាប្រភេទនេះ ប្រើជាមួយភ្លើងសញ្ញាចរាចរណ៍បីព៌ណ៌ជារង្វង់ សម្រាប់បញ្ជា និងសម្រួលចរាចរណ៍ដល់ថ្មើរជើង ក្នុងការដើរឆ្លងកាត់ផ្លូវ។

<u>ពណ៌និមួយៗនៃភ្លើងសញ្ញា មានអត្ថន័យដូចខាងក្រោម:</u>

-ពណ៌ក្រហម ដែលមានរូបមនុស្សពណ៌ស ឈរខាងក្នុង (រូប **02a.**):

ត្រូវឈប់, ហាមឆ្លងកាត់ ។

-ពណ៌បៃតង ដែលមានរូបមនុស្សពណ៌ស ដើរខាងក្នុង (រូប **02b.**):

អនុញ្ញាតអោយដើរឆ្លងកាត់បាន ។



03a. 03b. 03c.

## ភ្លើងសញ្ញាចរាចរណ៍បីព័ណ៌ ជាព្រួញ (ទៅមុខត្រង់)

THREE COLORED ARROW LIGHTS (STRAIGHT THROUGHT)

**លេខកូដ** : **PW03-L1-03**

**ខ្លឹមសារ** : ភ្លើងសញ្ញានេះ ប្រើនៅត្រង់ផ្លូវប្រសព្វ សម្រាប់បញ្ជា និងសម្រួលចរាចរណ៍ ដល់គន្លងផ្លូវនីមួយៗ ដែលអនុញ្ញាតឱ្យធ្វើចរាចរ តែទៅមុខត្រង់។ ព័ណ៌នីមួយៗនៃភ្លើងសញ្ញាចរាចរណ៍នេះ (រូប 03a. 03b. 03c.) មានអត្ថន័យដូចភ្លើងសញ្ញា បីព័ណ៌ ជារង្វង់ដែរ។



04a. 04b. 04c.

## ភ្លើងសញ្ញាចរាចរណ៍បីព័ណ៌ ជាព្រួញ (បត់ស្តាំ)

THREE COLORED ARROW LIGHTS (RIGHT TURN)

**លេខកូដ** : **PW03-L1-04**

**ខ្លឹមសារ** : ភ្លើងសញ្ញានេះ ប្រើនៅត្រង់ផ្លូវប្រសព្វ សម្រាប់បញ្ជា និងសម្រួលចរាចរណ៍ ដល់គន្លងផ្លូវនៅខាងស្តាំ ដែលអនុញ្ញាតឱ្យធ្វើចរាចរ បានតែបត់ស្តាំ។ ព័ណ៌នីមួយៗនៃភ្លើងសញ្ញាចរាចរណ៍នេះ (រូប 04a. 04b. 04c.)មានអត្ថន័យដូចភ្លើងសញ្ញា បីព័ណ៌ ជារង្វង់ដែរ។



05a. 05b. 05c.

## ភ្លើងសញ្ញាចរាចរណ៍បីព័ណ៌ ជាព្រួញ (បត់ឆ្វេង)

THREE COLORED ARROW LIGHTS (LEFT TURN)

**លេខកូដ** : **PW03-L1-04**

**ខ្លឹមសារ** : ភ្លើងសញ្ញានេះ ប្រើនៅត្រង់ផ្លូវប្រសព្វ សម្រាប់បញ្ជា និងសម្រួលចរាចរណ៍ ដល់គន្លងផ្លូវនៅខាងឆ្វេងដែលអនុញ្ញាតឱ្យធ្វើចរាចរ បានតែបត់ឆ្វេង។ ព័ណ៌នីមួយៗនៃភ្លើងសញ្ញាចរាចរណ៍នេះ (រូប 04a.04b. 04c.)មានអត្ថន័យដូចភ្លើងសញ្ញា បីព័ណ៌ ជារង្វង់ដែរ។



06a. 06b. 06c.

## ភ្លើងសញ្ញាចរាចរណ៍បីព័ណ៌ ជាព្រួញ (ទៅមុខត្រង់ និងបត់ស្តាំ)

THREE COLORED ARROW LIGHTS
(STRAIGHT THROUGHT AND RIGHT TURN)

**លេខកូដ** : **PW03-L1-06**

**ខ្លឹមសារ** : ភ្លើងសញ្ញានេះ ប្រើនៅត្រង់ផ្លូវប្រសព្វ សម្រាប់បញ្ជា និង សម្រួលចរាចរណ៍ ដល់គន្លងផ្លូវនីមួយៗ ដែលអនុញ្ញាតឱ្យធ្វើចរាចរ តែទៅមុខត្រង់ ឬ បត់ស្តាំ។

ព័ណ៌នីមួយៗនៃភ្លើងសញ្ញាចរាចរណ៍នេះ (រូប 06a. 06b. 06c.) មានអត្ថន័យដូចភ្លើងសញ្ញា បីព័ណ៌ ជារង្វង់ដែរ។

---



07a. 07b. 07c.

## ភ្លើងសញ្ញាចរាចរណ៍បីព័ណ៌ ជាព្រួញ (ទៅមុខត្រង់ និងបត់ឆ្វេង)

THREE COLORED ARROW LIGHTS
(STRAIGHT THROUGHT AND LEFT TURN)

**លេខកូដ** : **PW03-L1-07**

**ខ្លឹមសារ** : ភ្លើងសញ្ញានេះ ប្រើនៅត្រង់ផ្លូវប្រសព្វ សម្រាប់បញ្ជា និង សម្រួលចរាចរណ៍ ដល់គន្លងផ្លូវនីមួយៗ ដែលអនុញ្ញាតឱ្យធ្វើចរាចរ តែទៅមុខត្រង់ ឬ បត់ឆ្វេង។

ព័ណ៌នីមួយៗនៃភ្លើងសញ្ញាចរាចរណ៍នេះ (រូប 07a. 07b. 07c.) មានអត្ថន័យដូចភ្លើងសញ្ញា បីព័ណ៌ ជារង្វង់ដែរ។

---




08a. 08b.

## ភ្លើងសញ្ញាចរាចរណ៍ សម្រាប់ថ្មើរជើងឆ្លងកាត់ (ប្រើជាមួយ ភ្លើងសញ្ញាចរាចរណ៍បីព័ណ៌ ជាព្រួញ)

PEDESTRIAN CROSSING LIGHTS
(USED WITH THREE COLORED ARROW LIGHTS)

**លេខកូដ** : **PW03-L1-08**

**ខ្លឹមសារ** : ភ្លើងសញ្ញានេះ ប្រើជាមួយភ្លើងសញ្ញាចរាចរណ៍ បីព័ណ៌ ជាព្រួញ សម្រាប់បញ្ជា និងសម្រួលចរាចរណ៍ដល់ថ្មើរជើង ក្នុងការដើរឆ្លងកាត់ផ្លូវ។

**ព័ណ៌នីមួយៗនៃភ្លើងសញ្ញា មានអត្ថន័យដូចខាងក្រោម:**

- លេខ និង រូបមនុស្សឈរ ព័ណ៌ក្រហម លើផ្ទៃព័ណ៌ខ្មៅ (រូប **08a.**): **ត្រូវឈប់** ឬ **ហាមឆ្លងកាត់**។ លេខព័ណ៌ក្រហម ប្រាប់ពីរយៈពេលគិតជាវិនាទី ដែលនឹងប្តូរមកជា ព័ណ៌បៃតងវិញ។
- លេខ និង រូបមនុស្សធ្វើចលនា ព័ណ៌ខៀវ លើផ្ទៃព័ណ៌ខ្មៅ (រូប **08b.**): **អនុញ្ញាតឱ្យដើរឆ្លងកាត់បាន**។ លេខព័ណ៌បៃតង ប្រាប់ពីរយៈពេលគិតជាវិនាទី ដែលនឹងប្តូរមកជា ព័ណ៌ក្រហមវិញ។

## ប្រភេទ ទី២ : ភ្លើងសញ្ញាចរាចរណ៍ ពីរពណ៌ (Two Color Traffic Lights)



09a. 09b.

### ភ្លើងសញ្ញាចរាចរណ៍ពីរពណ៌ ជារង្វង់
### TWO COLORED CIRCULAR LIGHTS

**លេខកូដ :PW03-L1-09**

**ខ្លឹមសារ :** ភ្លើងសញ្ញាប្រភេទនេះ ប្រើសំរាប់ បញ្ជាអ្នកបើកបរយានជំនិះ នៅត្រង់បញ្ឈរបង់ប្រាក់ ថ្លៃប្រើប្រាស់ផ្លូវ ឬ ច្រកចេញ-ចូល ដែលចាំបាច់ ។

ពណ៌និមួយៗនៃភ្លើងសញ្ញា មានអត្ថន័យដូចខាងក្រោម:

-ក្រហម (រូប **09a.** ) ត្រូវឈប់ ។

-បៃតង (រូប **09b.** ) បន្តដំណើរ ។

## ប្រភេទ ទី៣ : ភ្លើងសញ្ញាចរាចរណ៍ មួយពណ៌ ភ្លឹបភ្លែតៗ
## ( One Colored Flashing Traffic Lights )



### ភ្លើងសញ្ញាពណ៌ក្រហម ភ្លឹបភ្លែតៗ
RED FLASHING LIGHT

**លេខកូដ :PW03-L1-10**

**ខ្លឹមសារ :** ភ្លើងសញ្ញា ពណ៌ក្រហម ភ្លឹបភ្លែត១ សំរាប់បញ្ជាអោយអ្នកបើកបរ យានជំនិះ គ្រប់ប្រភេទ **ឈប់** ។
ភ្លើងសញ្ញាប្រភេទនេះ ប្រើនៅត្រង់កំណាត់ផ្លូវដែលមានផ្លូវរថភ្លើងឆ្លងកាត់ ឬ នៅលើផ្លូវដែលជាកន្លែងបញ្ឈប់យានជំនិះ ដើម្បីធ្វើការត្រួតពិនិត្យ ។

---



### ភ្លើងសញ្ញាពណ៌លឿង ភ្លឹបភ្លែតៗ
YELLOW FLASHING LIGHT

**លេខកូដ :PW03-L1-11**

**ខ្លឹមសារ :** ភ្លើងសញ្ញា ពណ៌លឿង ភ្លឹបភ្លែត១ សំរាប់បញ្ជាអោយអ្នកបើកបរ យានជំនិះ គ្រប់ប្រភេទ បន្ថយល្បឿន ហើយប្រុងប្រយត្ន័ ។
ភ្លើងសញ្ញា ប្រភេទនេះច្រើនប្រើ នៅកន្លែងមានការដ្ឋានកន្លែងកំពុងមានឧបសគ្គ នៅលើទ្រូងផ្លូវ ឬ ត្រង់ផ្លូវប្រសព្វ ។

---

# គ - គំនូសសញ្ញាចរាចរណ៍

## ROAD MARKINGS

គំនូសសញ្ញាចរាចរណ៍ ត្រូវបានបង្កើតឡើងក្នុងគោលបំណង ធ្វើឱ្យចរាចរណ៍លើផ្លូវសាធារណៈ មានរបៀបរៀបរយ ងាយស្រួលក្នុងការបើកបរ និងធានាសុវត្ថិភាព។ គំនូសសញ្ញាចរាចរណ៍ទាំងនេះ អាចត្រូវបានគេប្រើតែឯង ឬ ជាមួយផ្លាកសញ្ញាផ្សេងៗទៀត ដើម្បីបង្ហាញ ឬ បញ្ជាក់អត្ថន័យឱ្យកាន់តែច្បាស់ដូចជា ការបែងចែកទិសចរាចរណ៍ ការបែងចែកទ្រូងផ្លូវ ការកំណត់ជាយផ្លូវ ប្រាប់អ្នកបើកបរឱ្យធ្វើដំណើរទៅតាមទិស ដែលត្រូវធ្វើចរាចរ សម្រាប់តម្រឹមគន្លងផ្លូវ សម្រាប់ថ្មើរជើងឆ្លងកាត់ សម្រាប់រថយន្តចតជាដើម។ គំនូសសញ្ញាចរាចរណ៍ ត្រូវបានបែងចែកជាប្រភេទផ្សេងៗពីគ្នាច្បាស់លាស់។

គំនូសសញ្ញាចរាចរណ៍ ចែកជា បួន ផ្នែកគឺ ៖

**ផ្នែក ទី I** : គំនូសចរាចរណ៍កាត់ទទឹងផ្លូវ (Transverse Marking)

លេខសម្គាល់ **PW03-M1-00**

**ផ្នែក ទី II** : គំនូសចរាចរណ៍តាមបណ្តោយទ្រូងផ្លូវ (Longitudinal Marking)

លេខសម្គាល់ **PW03-M2-00**

**ផ្នែក ទី III** : គំនូសសញ្ញាព្រួញលើទ្រូងផ្លូវ (Arrows Marking)

លេខសម្គាល់ **PW03-M3-00**

**ផ្នែក ទី IV** : គំនូសសញ្ញាផ្សេងៗលើទ្រូងផ្លូវ (Others Road Marking)

លេខសម្គាល់ **PW03-M4-00**

# ផ្នែកទី I

# គំនូសសញ្ញាពណ៌សកាត់ទទឹងផ្លូវ

# Transverse Markings

គំនូសសញ្ញាពណ៌ស កាត់ទទឹងផ្លូវ ជាខ្សែគំនូស ដែលជាប់ ឬ ដាច់ៗ ទោល ឬ ភ្លោះ ទៅតាមប្រភេទគំនូសសញ្ញានិមួយៗ ។

គំនូសសញ្ញាប្រភេទនេះ មាននៅកន្លែងជិតចូលផ្លូវប្រសព្វ ឬ រង្វង់មូល ដែលមានផ្លាកសញ្ញា បាត់សិទ្ធិដូចជាសញ្ញា **ឈប់** ឬសញ្ញា **ផ្តល់សិទ្ធិអាទិភាពអោយគេ** សំរាប់កំណត់ទីតាំង អោយអ្នកបើកបរឈប់នៅត្រឹមមុខគំនូសនេះ មុននឹងបន្តដំណើរ ចូលក្នុងផ្លូវធំមានសិទ្ធិអាទិភាព ឬ រង្វង់មូល ។

# ផ្នែកទី I : គំនូសសញ្ញាពណ៌ស កាត់ទទឹងទ្រូងផ្លូវ ( Transverse Markings )



**គំនូសសញ្ញាឈប់ (ទោល)**
STOP LINE (SINGLE SOLID)

**លេខកូដ :PW03-M1-01**

**ខ្លឹមសារ :** គំនូសសញ្ញាទោល ជាប់ ពណ៌ស កាត់ទទឹងទ្រូងផ្លូវ ប្រើសំរាប់ កំណត់ទីតាំងអោយអ្នកបើកបរឈប់ នៅត្រឹមមុខគំនូសនេះ នៅត្រង់ផ្លូវប្រសព្វ ដែលបញ្ជាដោយភ្លើងសញ្ញា ចរាចរ ។

---



**គំនូសសញ្ញាឈប់ (ភ្លោះ)**
STOP LINE (DOUBLE SOLID)

**លេខកូដ :PW03-M1-02**

**ខ្លឹមសារ :** គំនូសសញ្ញាភ្លោះ ជាប់ពណ៌ស កាត់ទទឹងទ្រូងផ្លូវ ប្រើសំរាប់ កំណត់ទីតាំងអោយអ្នកបើកបរឈប់ នៅត្រឹមមុខគំនូសនេះ នៅត្រង់ផ្លូវប្រសព្វ ដែលមានផ្លាកសញ្ញា **ឈប់ដើម្បី ផ្តល់សិទ្ធិអាទិភាពអោយគេ** និង គ្មានភ្លើងសញ្ញាចរាចរ ។

---



**គំនូសសញ្ញាផ្តល់សិទ្ធិអាទិភាព (ភ្លោះ)**
GIVE WAY LINE (DOUBLE BROKEN)

**លេខកូដ :PW03-M1-03**

**ខ្លឹមសារ :** គំនូសសញ្ញាភ្លោះ ដាច់ៗពណ៌ស កាត់ទទឹងទ្រូងផ្លូវ ប្រើសំរាប់ កំណត់ទីតាំងអោយអ្នកបើកបរឈប់ នៅត្រឹមមុខគំនូសនេះ នៅត្រង់ផ្លូវប្រសព្វ ដែលមានផ្លាកសញ្ញា **ផ្តល់សិទ្ធិ អាទិភាពអោយគេ** និង គ្មានភ្លើងសញ្ញាចរាចរ ។

---



**គំនូសសញ្ញាផ្តល់សិទ្ធិអាទិភាព (ទោល)**
GIVE WAY LINE (SINGLE BROKEN)

**លេខកូដ :PW03-M1-04**

**ខ្លឹមសារ :** គំនូសសញ្ញាទោល ដាច់ៗពណ៌ស កាត់ទទឹងទ្រូងផ្លូវ ប្រើសំរាប់ កំណត់ទីតាំងអោយអ្នកបើកបរឈប់ នៅត្រឹមមុខគំនូសនេះ នៅត្រង់ផ្លូវចូលរង្វង់មូល ដែលមានផ្លាកសញ្ញា **ផ្តល់សិទ្ធិអាទិភាពអោយគេនៅរង្វង់មូល** ។

# ផ្នែកទី II

# គំនូសសញ្ញាតាមបណ្ដោយទ្រូងផ្លូវ

## ( Longitudinal Markings )

គំនូសសញ្ញា តាមបណ្ដោយទ្រូងផ្លូវ ជាខ្សែគំនូសជាប់ ឬ ដាច់ៗ ទោល ឬ ភ្លោះ ពណ៌លឿង ស ឬ ក្រហម ទៅតាមប្រភេទ គំនូសសញ្ញានិមួយៗ ។ ការបើកបរជាន់ពីលើ តាមបណ្ដោយគំនូសសញ្ញាប្រភេទនេះ ត្រូវហាមឃាត់ ។

# ផ្នែកទី II : គំនូសសញ្ញាតាមបណ្តោយទ្រូងផ្លូវ ( Longitudinal Markings )



**គំនូសសញ្ញាទោលដាច់ៗ បែងចែកទិសចរាចរ**

SINGLE YELLOW BROKEN LINE

**លេខកូដ :PW03-M2-01**

**ខ្លឹមសារ :** គំនូសសញ្ញាទោលដាច់ៗ ពណ៌លឿង តាមបណ្តោយទ្រូងផ្លូវ ប្រើសំរាប់បែងចែកទ្រូងផ្លូវ ជាពីរ ទិសចរាចរផ្ទុយគ្នា អ្នកបើកបរអាចឆ្លងកាត់ ឬ ជែងបាន ។

---



**គំនូសសញ្ញាទោលជាប់ បែងចែកទិសចរាចរ**

SINGLE YELLOW SOLID LINE

**លេខកូដ :PW03-M2-02**

**ខ្លឹមសារ :** គំនូសសញ្ញាទោលជាប់ ពណ៌លឿង តាមបណ្តោយ ទ្រូងផ្លូវ ប្រើសំរាប់បែងចែកទ្រូងផ្លូវ ជាពីរ ទិសចរាចរផ្ទុយគ្នា និង ហាមបើកបរជាន់ ឬឆ្លងកាត់ ។ គំនូសសញ្ញានេះ ប្រើលើផ្លូវដែលមានចរាចរធម្មតា ។

---



**គំនូសសញ្ញាភ្លោះជាប់ បែងចែកទិសចរាចរ**

DOUBLE YELLOW SOLID LINE

**លេខកូដ :PW03-M2-03**

**ខ្លឹមសារ :** គំនូសសញ្ញាភ្លោះជាប់ ពណ៌លឿង តាមបណ្តោយទ្រូងផ្លូវ ប្រើសំរាប់បែងចែកទ្រូងផ្លូវ ជាពីរ ទិសចរាចរផ្ទុយគ្នា និង ហាមបើកបរជាន់ ឬឆ្លងកាត់ ។ គំនូសសញ្ញានេះ ប្រើលើផ្លូវដែលមានចរាចរច្រើន ឬនៅត្រង់ផ្លូវកោងគ្រោះថ្នាក់ ឬត្រង់ស្ពាន។

---



**គំនូសសញ្ញាភ្លោះ បែងចែកទិសចរាចរ**
**(មានគំនូសដាច់ៗនៅខាងឆ្វេង)**

DOUBLE YELLOW COMBINATION LINE

**លេខកូដ :PW03-M2-04**

**ខ្លឹមសារ :** គំនូសសញ្ញាភ្លោះ ពណ៌លឿង ដែលមានគំនូសដាច់ៗ នៅខាងឆ្វេង និង គំនូសជាប់នៅខាងស្តាំ តាមបណ្តោយទ្រូងផ្លូវ ប្រើសំរាប់បែងចែកទ្រូងផ្លូវ ជាពីរទិសចរាចរផ្ទុយគ្នា ។ អ្នកបើកបរ នៅក្បែរគំនូសដាច់ៗ អាចឆ្លងកាត់ ឬ ជែងបាន ប៉ុន្តែអ្នកបើកបរនៅក្បែរគំនូសជាប់ មិនអាចឆ្លងកាត់ ឬ ជាន់បានឡើយ ។



## គំនូសសញ្ញាភ្លោះ បែងចែកទិសចរាចរ (មានគំនូសដាច់ៗនៅខាងស្តាំ)

DOUBLE YELLOW COMBINATION LINE

**លេខកូដ ៖ PW03-M2-05**

**ខ្លឹមសារ ៖** គំនូសសញ្ញាភ្លោះ ព័ណ៌លឿង ដែលមានគំនូសដាច់ៗនៅខាងស្តាំ និង គំនូសជាប់នៅខាងឆ្វេង តាមបណ្តោយទ្រូងផ្លូវ ប្រើសម្រាប់បែងចែកទ្រូងផ្លូវ ជាពីរទិសចរាចរផ្ទុយគ្នា។ អ្នកបើកបរនៅកៀកគំនូសដាច់ៗ អាចឆ្លងកាត់ ឬ ជែងបាន ប៉ុន្តែអ្នកបើកបរនៅកៀក គំនូសជាប់ មិនអាចឆ្លងកាត់ ឬ ជាន់ បានឡើយ។

---



## គំនូសសញ្ញាដាច់ៗ បែងចែកគន្លងផ្លូវ

SINGLE WHITE BROKEN LINE

**លេខកូដ ៖ PW03-M2-06**

**ខ្លឹមសារ ៖** គំនូសសញ្ញាដាច់ៗ ទោលព័ណ៌ស តាមបណ្តោយទ្រូងផ្លូវ ប្រើសម្រាប់បែងចែកគន្លងផ្លូវចរាចរ។ អ្នកបើកបរ អាចឆ្លងកាត់ ប្តូរគន្លងផ្លូវបាន។

---



## គំនូសសញ្ញាជាប់ បែងចែកគន្លងផ្លូវ

WHITE SINGLE SOLID LINE

**លេខកូដ ៖ PW03-M2-07**

**ខ្លឹមសារ ៖** គំនូសសញ្ញាជាប់ទោល ព័ណ៌ស តាមបណ្តោយទ្រូងផ្លូវ ប្រើសម្រាប់បែងចែកគន្លងផ្លូវចរាចរនៅជិតផ្លូវប្រសព្វ។ អ្នកបើកបរមិនត្រូវឆ្លងកាត់គំនូសនេះ ដើម្បីប្តូរគន្លងផ្លូវឡើយ។

---



## គំនូសសញ្ញា កំណត់ជាយផ្លូវ

EDGE LINE

**លេខកូដ ៖ PW03-M2-08**

**ខ្លឹមសារ ៖** គំនូសសញ្ញាជាប់ទោល ព័ណ៌ស តាមបណ្តោយជាយផ្លូវ ប្រើសម្រាប់កំណត់ជាយផ្លូវអោយយានជំនិះធ្វើចរាចរ។



## គំនូសសញ្ញាគោល លឿង-ស លើគែមចិញ្ចើមផ្លូវ
YELLOW-WHITE CURB MARKINGS

**លេខកូដ ៖ PW03-M2-09**

**ខ្លឹមសារ ៖** គំនូសសញ្ញា ព័ណ៌លឿង-ស តាមបណ្ដោយគែមចិញ្ចើមផ្លូវ ប្រើសម្រាប់ ការហាមចត។

---



## គំនូសសញ្ញាគោល ក្រហម-ស លើគែមចិញ្ចើមផ្លូវ
RED-WHITE CURB MARKINGS

**លេខកូដ ៖ PW03-M2-10**

**ខ្លឹមសារ ៖** គំនូសសញ្ញា ព័ណ៌ក្រហម-ស តាមបណ្ដោយគែមចិញ្ចើមផ្លូវ ប្រើសម្រាប់ ការហាមឈប់។

---



## គំនូសសញ្ញា ខ្មៅ-លឿង លើខឿនទ្រូងផ្លូវ
BLACK-YELLOW ROAD ISLAND

**លេខកូដ ៖ PW03-M2-11**

**ខ្លឹមសារ ៖** គំនូសសញ្ញាខ្មៅ-លឿង លើខឿនទ្រូងផ្លូវ ប្រើសម្រាប់ អោយអ្នកបើកបរប្រុងប្រយ័ត្ន មានខឿនលើទ្រូងផ្លូវ។

# ផ្នែកទី III

# គំនូសសញ្ញាព្រួញលើទ្រូងផ្លូវ

# ( Arrows Markings )

គំនូសសញ្ញា ព្រួញលើទ្រូងផ្លូវ ( ជាទូទៅលើគន្លងផ្លូវ )មានពណ៌ស សំរាប់អោយអ្នកបើកបរ ធ្វើចរាចរទៅតាមទិសដៅ ដែលចង្អុលប្រាប់របស់ព្រួញ ។ គំនូសសញ្ញានេះ ប្រើនៅពេលខិតជិតដល់ផ្លូវប្រសព្វ ឬ នៅពេលខិតជិតដល់គន្លងផ្លូវដែល រួមចូលទៅគន្លងផ្សេង ដើម្បីអោយអ្នកបើកបរ ដឹងជាមុន ងាយស្រួលប្តូរគន្លងផ្លូវ ទៅតាមទិសដែលខ្លួនចង់ទៅ ។

# ផ្នែកទី III : គំនូសសញ្ញាព្រួញលើផ្ទៃផ្លូវ ( Arrows Markings )



## គំនូសសញ្ញាព្រួញទៅមុខត្រង់

STRAIGTH ARROW

**លេខកូដ :PW03-M3-01**

**ខ្លឹមសារ :** គំនូសសញ្ញាព្រួញពណ៌ស ទៅមុខត្រង់ ប្រើសំរាប់អោយអ្នកបើកបរដឹងថា នៅត្រង់ផ្លូវប្រសព្វខាងមុខ គន្លងផ្លូវនេះ សំរាប់ធ្វើ ចរាចរទៅមុខត្រង់ តែប៉ុណ្ណោះ ។

---



## គំនូសសញ្ញាព្រួញទៅមុខត្រង់ និង បត់ស្តាំ

TURN RIGHT AND STRAIGTH ARROW

**លេខកូដ :PW03-M3-02**

**ខ្លឹមសារ :** គំនូសសញ្ញាព្រួញពណ៌ស ទៅមុខត្រង់ និង បត់ស្តាំ ប្រើសំរាប់អោយអ្នកបើកបរដឹងថា នៅត្រង់ផ្លូវប្រសព្វខាងមុខ គន្លងផ្លូវនេះសំរាប់ធ្វើចរាចរទៅមុខត្រង់ និង បត់ទៅស្តាំ តែប៉ុណ្ណោះ ។

---



## គំនូសសញ្ញាព្រួញទៅមុខត្រង់ និង បត់ឆ្វេង

TURN LEFT AND STRAIGTH ARROW

**លេខកូដ :PW03-M3-03**

**ខ្លឹមសារ :** គំនូសសញ្ញាព្រួញពណ៌ស ទៅមុខត្រង់ និង បត់ឆ្វេង ប្រើសំរាប់អោយអ្នកបើកបរដឹងថា នៅត្រង់ផ្លូវប្រសព្វខាងមុខ គន្លងផ្លូវនេះសំរាប់ធ្វើចរាចរទៅមុខត្រង់ និង បត់ទៅ ឆ្វេង តែប៉ុណ្ណោះ ។

---



## គំនូសសញ្ញាព្រួញ បត់ស្តាំ

TURN RIGHT ARROW

**លេខកូដ :PW03-M3-04**

**ខ្លឹមសារ :** គំនូសសញ្ញាព្រួញពណ៌ស បត់ទៅខាងស្តាំ ប្រើសំរាប់អោយអ្នកបើកបរដឹងថា នៅត្រង់ផ្លូវប្រសព្វខាងមុខ គន្លងផ្លូវនេះសំរាប់ធ្វើចរាចរ បត់ទៅស្តាំ តែប៉ុណ្ណោះ ។



**គំនូសសញ្ញាព្រួញ បត់ឆ្វេង**

TURN LEFT ARROW

**លេខកូដ :PW03-M3-05**

**ខ្លឹមសារ :** គំនូសសញ្ញាព្រួញពណ៌ស បត់ទៅខាងឆ្វេង ប្រើសំរាប់អោយអ្នកបើកបរដឹងថា នៅត្រង់ផ្លូវប្រសព្វខាងមុខ គន្លងផ្លូវនេះសំរាប់ធ្វើចរាចរ បត់ទៅឆ្វេង តែប៉ុណ្ណោះ ។

---



**គំនូសសញ្ញាព្រួញ ងាកស្តាំ**

**(នៅចន្លោះគំនូសទោល ដាច់ៗ បែងចែកទិសចរាចរ)**

KEEP RIGHT ARROW

**លេខកូដ :PW03-M3-06**

**ខ្លឹមសារ :** គំនូសសញ្ញា ព្រួញពណ៌សងាកស្តាំ ដែលនៅចន្លោះគំនូសទោលដាច់ៗ ពណ៌លឿង ប្រើសំរាប់អោយដំណឹងថា នៅខាងមុខមានគំនូសជាប់ (ទោល ឬ ភ្លោះ ) ពណ៌លឿង ។ អ្នកបើកបរ បើឃើញគំនូសសញ្ញានេះ ត្រូវងាកមកគន្លងខាងស្តាំតាមគំនូសសញ្ញាព្រួញនេះ ។

---



**គំនូសសញ្ញាព្រួញ ងាកស្តាំ (លើគន្លងផ្លូវ )**

KEEP RIGHT ARROW

**លេខកូដ :PW03-M3-07**

**ខ្លឹមសារ :** គំនូសសញ្ញា ព្រួញពណ៌សងាកស្តាំ នៅលើគន្លងផ្លូវប្រើសំរាប់អោយដំណឹងថា នៅខាងមុខ គន្លងផ្លូវនេះ នឹងរួមចូលទៅ គន្លងផ្លូវខាងស្តាំតែមួយ ។

---



**គំនូសសញ្ញាព្រួញ ងាកឆ្វេង (លើគន្លងផ្លូវ )**

KEEP LEFT ARROW

**លេខកូដ :PW03-M3-08**

**ខ្លឹមសារ :** គំនូសសញ្ញា ព្រួញពណ៌សងាកឆ្វេង នៅលើគន្លងផ្លូវប្រើសំរាប់អោយដំណឹងថា នៅខាងមុខ គន្លងផ្លូវនេះ នឹងរួមចូលទៅ គន្លងផ្លូវខាងឆ្វេងតែមួយ ។

# ផ្នែកទី IV

# គំនូសសញ្ញាផ្សេងៗ លើផ្ទៃផ្លូវ

## ( Other Road Markings )

គំនូសសញ្ញានេះមានរាងខុសៗគ្នា មានពណ៌ស ឬពណ៌លឿង ទៅតាមប្រភេទគំនូសសញ្ញានិមួយៗ ។

គំនូសសញ្ញាប្រភេទនេះត្រូវបានគេប្រើ សំរាប់គូសតំរឹមគន្លងផ្លូវ សំរាប់ថ្មើរជើងឆ្លងកាត់ សំរាប់រថយន្តចត សំរាប់រថយន្តក្រុងឈប់ ជាដើម ។ល។

## ផ្នែកទី IV. : គំនូសសញ្ញាផ្សេងៗ លើថ្នល់ផ្លូវ ( Other Road Markings )



### គំនូសសញ្ញាតំរឹមគន្លងផ្លូវ (ផ្លូវមានចរាចរណ៍ពីរទិស )

DIAGONAL HATCHED MARKINGS (TWO-WAY ROAD)

**លេខកូដ :PW03-M4-01**

**ខ្លឹមសារ :** គំនូសសញ្ញាពណ៌លឿង ឆ្នូតបញ្ឆិតទ្រូងផ្លូវ ប្រើសំរាប់ តំរឹមគន្លងផ្លូវ ដែលមានចរាចរ ពីរទិសផ្ទុយគ្នា ។ ហាមបើកបរជាន់ ឆ្លងកាត់ ឈប់ ឬ ចតលើគំនូសសញ្ញានេះ ។

---



### គំនូសសញ្ញាតំរឹមគន្លងផ្លូវ (ផ្លូវឯកទិស )

CHEVRON MARKINGS (ONE-WAY ROAD)

**លេខកូដ :PW03-M4-02**

**ខ្លឹមសារ :** គំនូសសញ្ញាពណ៌លឿង រាងមុខព្រួញ លើទ្រូងផ្លូវ ប្រើសំរាប់ តំរឹមគន្លងផ្លូវ ដែលមានចរាចរ តែមួយទិស ។ ហាមបើកបរជាន់ ឆ្លងកាត់ ឈប់ ឬ ចតលើគំនូសសញ្ញានេះ ។

---



### គំនូសសញ្ញាតំរឹមថ្នល់ផ្លូវ (ជាប់គែមចិញ្ចើមផ្លូវ )

DIAGONAL HATCHED MARKINGS (ON ROAD EDGE)

**លេខកូដ :PW03-M4-03**

**ខ្លឹមសារ :** គំនូសសញ្ញាពណ៌ស ឆ្នូតបញ្ឆិតគែមចិញ្ចើមផ្លូវ ប្រើសំរាប់ តំរឹមទ្រូងផ្លូវចរាចរ ដូចជានៅចុងសងខាងកន្លែងចត រថយន្ត ឬ កន្លែងចាំបាច់ផ្សេងទៀត ។ ហាមបើកបរជាន់ ឆ្លងកាត់ ឈប់ ឬ ចតលើគំនូសសញ្ញានេះ ។

---



### គំនូសសញ្ញា សំរាប់ថ្មើរជើងឆ្លងកាត់

CROSSWALK MARKINGS

**លេខកូដ :PW03-M4-04**

**ខ្លឹមសារ :** គំនូសសញ្ញាពណ៌ស កាត់ទទឹងទ្រូងផ្លូវ ជាកង់ៗ ប្រើសំរាប់ ថ្មើរជើងឆ្លងកាត់ ។ ហាមយានជំនិះគ្រប់ប្រភេទ ឈប់ ឬ ចត ពីលើគំនូសសញ្ញានេះ ។



**គំនូសសញ្ញា លើទួល**

ROAD HUMP MARKINGS

**លេខកូដ :PW03-M4-05**

**ខ្លឹមសារ :** គំនូសសញ្ញាពណ៌លឿងឆ្នូតខ្មៅ បញ្ឆិតកាត់ទទឹងទ្រូងផ្លូវ ប្រើសំរាប់អោយអ្នកបើកបរប្រុងប្រយត្ន័ មានទួលនៅត្រង់ គំនូសនេះ ។

---



**គំនូសសញ្ញា សំរាប់រថយន្តក្រុងឈប់**

BUS STOP MARKINGS

**លេខកូដ :PW03-M4-06**

**ខ្លឹមសារ :** គំនូសសញ្ញាពណ៌លឿង រាងធ្មេញរណា ប្រើដើម្បីកំណត់ទីកន្លែង សំរាប់តែរថយន្តក្រុង ឈប់ ។

---



**គំនូសសញ្ញា សំរាប់រថយន្តចត (ស្របគែមចិញ្ចើមផ្លូវ)**

PARKING BAY MARKINGS (PARALLEL PARKINGS)

**លេខកូដ :PW03-M4-07**

**ខ្លឹមសារ :** គំនូសសញ្ញាដាច់ៗពណ៌ស រាងចតុកោណកែង ដែលមានជ្រុងវែង ស្របទៅនឹងគែមចិញ្ចើមផ្លូវ ប្រើដើម្បីកំណត់ទីកន្លែង អោយរថយន្តចត ក្នុងចន្លោះសញ្ញានេះ ។

---



**គំនូសសញ្ញា សំរាប់រថយន្តចត (កែងគែមចិញ្ចើមផ្លូវ)**

PARKING BAY MARKINGS (VERTICAL PARKINGS)

**លេខកូដ :PW03-M4-08**

**ខ្លឹមសារ :** គំនូសសញ្ញា ពណ៌ស រាងចតុកោណកែង ដែលមានជ្រុងវែងជាគំនូសជាប់ ហើយកែងទៅនឹងគែមចិញ្ចើមផ្លូវ ប្រើដើម្បីកំណត់ទីកន្លែង អោយរថយន្តចត ក្នុងចន្លោះសញ្ញានេះ ។



## គំនូសសញ្ញា សំរាប់រថយន្តចត (បញ្ឆិតគែមចិញ្ចើមផ្លូវ)

PARKING BAY MARKINGS (ANGLED PARKINGS)

**លេខកូដ :PW03-M4-09**

**ខ្លឹមសារ :** គំនូសសញ្ញា ពណ៌ស រាងចតុកោណ ដែលមាន ជ្រុងវែងជាគំនូសជាប់ ហើយបញ្ឆិតទៅនឹងគែមចិញ្ចើមផ្លូវ ប្រើដើម្បីកំណត់ទីកន្លែង អោយរថយន្តចត ក្នុងចន្លោះសញ្ញានេះ ។

# ឃ - សញ្ញាបញ្ជារបស់ភ្នាក់ងារនគរបាលចរាចរណ៍

## TRAFFIC POLICE SIGNALS

សញ្ញាបញ្ជាចរាចរណ៍របស់ភ្នាក់ងារនគរបាលចរាចរណ៍ ត្រូវបានបង្កើតឡើងក្នុងគោលបំណង ដើម្បីបង្កើនការសម្រួលចរាចរណ៍ដូចជា នៅពេលចរាចរណ៍ខ្លាំង ដែលអាចធ្វើអោយកកស្ទះ នៅពេលភ្លើងសញ្ញាចរាចរណ៍មិនដំណើរការ នៅពេលបញ្ជាពីលើទោចក្រយាន្ត ឱ្យយានបន្ថយល្បឿន ឬឈប់ ឬនៅពេលបញ្ជានាំមុខក្បួនដង្ហែផ្សេងៗ ។

# រូបភាពស្តីពី សញ្ញាបញ្ជារបស់ភ្នាក់ងារនគរបាលចរាចរណ៍



## រូបភាពបញ្ជាចរាចរណ៍មើលពីចំហៀង

មានន័យដូចភ្លើងសញ្ញាចរាចរណ៍ព័ណ៌បៃតង

**លេខកូដ** : **PW03-O1-01**

**ខ្លឹមសារ** : អ្នកបើកបរ មើលឃើញចំហៀងខ្លួនភ្នាក់ងារនគរបាលចរាចរ ដៃម្ខាង ឬ ដៃទាំងពីរ លាតសន្ធឹង តាមបណ្តោយស្មា យោលទៅតាមបន្ទាត់ផ្តេក
ជាសញ្ញាផ្លូវទំនេរអនុញ្ញាត

---



## រូបភាពបញ្ជាចរាចរណ៍មើលពីមុខ ឬ ពីក្រោយ

មានន័យដូចភ្លើងសញ្ញាចរាចរណ៍ព័ណ៌ក្រហម

**លេខកូដ** : **PW03-O1-02**

**ខ្លឹមសារ** : អ្នកបើកបរ មើលឃើញភ្នាក់ងារនគរបាលចរាចរពីមុខ ឬ ពីក្រោយ លាតដៃម្ខាង ឬ ដៃទាំងពីរសន្ធឹងតាមបណ្តោយស្មា យោលទៅតាមបន្ទាត់ផ្តេក ជាសញ្ញាត្រូវឈប់ដាច់ខាត ។

---



## រូបភាពបញ្ជាចរាចរណ៍មើលពីមុខ ឬ ពីក្រោយ

មានន័យដូចភ្លើងសញ្ញាចរាចរណ៍ព័ណ៌លឿង

**លេខកូដ** : **PW03-O1-03**

**ខ្លឹមសារ** : អ្នកបើកបរ មើលឃើញភ្នាក់ងារនគរបាលចរាចរពីមុខ ឬ ពីក្រោយ លើកដៃឡើងលើ បាតដៃលាទៅមុខបែរទៅរកយានជំនិះ ជាសញ្ញាអោយបើកបរ ដោយប្រុងប្រយ័ត្ន ។




**រូបភាពបញ្ជាចរាចរណ៍ផ្សេងៗ**

**លេខកូដ : PW03-O1-04**

**ខ្លឹមសារ** : ១. បន្ថែមល្បឿនទៅមុខ
២. ធ្វើដំណើរទៅមុខ
៣. យានជំនិះដែលនគរបាលចង្អុលនេះត្រូវ ឈប់ (ចូលចត)

---




**រូបភាពបញ្ជាចរាចរណ៍នៅពេលបើកបរនោចក្រយានយន្ត**

**លេខកូដ : PW03-O1-05**

**ខ្លឹមសារ** : ១. អែបស្តាំ
២. បន្ថយល្បឿន
៣. ឈប់